**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋសភា

# របាយការណ៍សង្ខេប
# ស្តីពីសកម្មភាពការងាររបស់រដ្ឋសភា
# នាចន្លោះសម័យប្រជុំរដ្ឋសភាលើកទី៥ និងលើកទី ៦ នីតិកាលទី ៦

- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អនុប្រធានទី១ នៃរដ្ឋសភា
- លោកជំទាវកិត្តិសង្គហបណ្ឌិត អនុប្រធានទី២ នៃរដ្ឋសភា
- សម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាដ៏ឧត្តុង្គឧត្តមនៃរដ្ឋសភា

ថ្ងៃនេះ ជាទិវាដ៏មាននក្ខត្តឫក្សមហាប្រសើរ ដែលសមាជិក សមាជិកានៃរដ្ឋសភាយើង បានអញ្ជើញមកជួបជុំគ្នាវិញ ដើម្បីបើកបវេសនកាលនៃសម័យប្រជុំរដ្ឋសភា លើកទី៦ នីតិកាលទី៦ នៃរដ្ឋសភា។

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះវត្តមាន សម្តេច ឯកឧត្តម លោកជំទាវ ដែលបានអញ្ជើញវិលត្រឡប់មកចូលរួមបំពេញការងារនៅរដ្ឋសភាយើងវិញ ក្រោយពីបានចុះបំពេញភារកិច្ចនៅតាមមណ្ឌល ក៏ដូចបំពេញបេសកកម្មផ្សេងៗ ក្នុងវិស្សមកាលកន្លងមកនេះ។

ដូចឯកឧត្តម លោកជំទាវ បានជ្រាបស្រាប់ហើយថា ការបើកសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ នេះ ដើមឡើយបានគ្រោងធ្វើនៅថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០២១ ។ ប៉ុន្តែដោយសារការផ្ទុះការឆ្លងនៃជំងឺកូវីដ-១៩ ជាច្រើន តាំងពីពេលនោះមក ទើបគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបាន សម្រេចបើកធ្វើការប្រជុំ នៅថ្ងៃនេះវិញ។

តទៅនេះ ខ្ញុំសូមជម្រាបជូនអង្គសភានូវរបាយការណ៍សង្ខេបស្តីពីសកម្មភាពការងាររបស់រដ្ឋសភា ចន្លោះសម័យប្រជុំរដ្ឋសភាលើកទី៥ និងលើកទី៦ នីតិកាលទី៦ មានជាអាទិ៍ សកម្មភាពរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ សកម្មភាព ការប្រជុំរដ្ឋសភាជាវិសាមញ្ញ សកម្មភាពការងារការទូតសភា សកម្មភាពក្នុងអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩ក្នុងសហគមន៍ព្រឹត្តិការណ៍២០កុម្ភៈ សកម្មភាពថ្នាក់ដឹកនាំរដ្ឋសភា និងសកម្មភាពគណៈកម្មការនីមួយៗនៃរដ្ឋសភា។

## I. សកម្មភាពគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា

ក្នុងចន្លោះសម័យប្រជុំលើកទី៥ និងលើកទី៦ នីតិកាលទី៦នេះ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បានបើកសម័យប្រជុំចំនួន០៥លើក គឺ ៖

ក/.សម័យប្រជុំ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ -គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បានពិនិត្យ និងអនុម័ត៖



វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៩ សារអេឡិចត្រូនិច:sg@nac.org.kh គេហទំព័រ: www.nac.org.kh

-ប្រគល់សេចក្តីព្រាងច្បាប់ ចំនួន៤ ជូនគណៈកម្មការទី២នៃរដ្ឋសភា ដោយសហការជាមួយគណៈកម្មការទី៩នៃរដ្ឋសភា ពិនិត្យពិភាក្សាហើយធ្វើរបាយការណ៍ជូនគណៈកម្មការអចិន្ត្រៃយ៍រដ្ឋសភាវិញ រួមមាន៖ ១/.សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុន **ស្មេរថេក ខូ អិលធីឌី** សម្រាប់គម្រោងអភិវឌ្ឍខ្សែបណ្តាញបញ្ជូនអគ្គិសនី តង់ស្យុង ៥០០គីឡូវ៉ុល ពីខេត្តបាត់ដំបង ទៅកាន់ព្រំដែនកម្ពុជា-ថៃ។ ២/.សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុន **ស្មេរថេក ខូ អិលធីឌី** សម្រាប់គម្រោងអភិវឌ្ឍខ្សែបណ្តាញបញ្ជូនអគ្គិសនីតង់ស្យុង ៥០០គីឡូវ៉ុល ពីរាជធានីភ្នំពេញ ទៅកាន់ព្រំដែនកម្ពុជា-ឡាវ ។ ៣/.សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុន **អគ្គិសនីវៀតណាមនៃសាធារណរដ្ឋសង្គមនិយមវៀតណាម** សម្រាប់ការធានាលើការទិញថាមពលអគ្គិសនីពីប្រទេសវៀតណាម។ ៤/.សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុន **ឆាយណា ណេសិនណល ហៅ ម៉ាស៊ីនណឺរី ឌបភើរេសិន** សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងតាតៃលើ អានុភាព ១៥០មេហ្គាវ៉ាត់ ខេត្តកោះកុង។

-ទទួលស្គាល់ **ឯកឧត្តម ខឹម ច័ន្ទគីរី** ជាតំណាងរាស្ត្រថ្មីមណ្ឌលខេត្តកណ្តាល ជំនួស **ឯកឧត្តម ង៉ោ សុវណ្ណ** ដែលបានសុំលាលែង។ ការប្រកាសសុពលភាពនៃអាណត្តិរបស់ **ឯកឧត្តម ខឹម ច័ន្ទគីរី** ជាសមាជិករដ្ឋសភានីតិកាលទី៦ នឹងធ្វើឡើងនៅក្នុងសម័យប្រជុំរដ្ឋសភា។

-ជ្រើសតាំង **លោកជំទាវ ពៅ សុភាព** ជាសមាជិកាគណៈកម្មការទី៦នៃរដ្ឋសភា ដើម្បីដាក់ជូនសម័យប្រជុំរដ្ឋសភា នាពេលខាងមុខ បោះឆ្នោតសុំសេចក្តីទុកចិត្ត។

-ប្រគល់សេចក្តីព្រាងច្បាប់ស្តីពី វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដល់គណៈកម្មការទី៨នៃរដ្ឋសភា ដោយសហការជាមួយគណៈកម្មការទី៦នៃរដ្ឋសភា ពិនិត្យសិក្សា ហើយធ្វើរបាយការណ៍ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាវិញ។

-យល់ព្រមកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ ដើម្បីពិនិត្យ ដើម្បីអនុម័តសេចក្តីព្រាងច្បាប់ស្តីពី វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

ខ/. **សម័យប្រជុំ ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១** -គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា បានពិនិត្យ និងអនុម័ត៖

-បញ្ចូលទៅក្នុងរបៀបវារៈសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ នូវសេចក្តីព្រាងច្បាប់ស្តីពី វិធានការទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

-អនុម័តសមាសភាពលេខាធិការ សម្រាប់សម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ ចំនួន៣រូប។

-អនុម័តកំណត់កាលបរិច្ឆេទបើកសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ ដោយមានរបៀបវារៈ ការពិភាក្សា និងអនុម័ត សេចក្តីព្រាងច្បាប់ស្តីពី វិធានការទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

គ/. សម័យប្រជុំ ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បានប្រព្រឹត្តទៅតាមរយៈប្រព័ន្ធវីដេអូ ដោយបានអនុម័តៈ

១-ប្រគល់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ ជូនគណៈកម្មការទី២ សហការជាមួយគណៈកម្មការទី៥ និងគណៈកម្មការទី៩នៃរដ្ឋសភា ពិនិត្យសិក្សា ហើយធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍វិញ។

២-ប្រគល់សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី វិសោធនកម្មមាត្រា១៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា១៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ជូនគណៈកម្មការទី២នៃរដ្ឋសភា ពិនិត្យសិក្សា ហើយធ្វើរបាយការណ៍ជូនគណៈកម្មការអចិន្ត្រៃវិញ។

៣-យល់ព្រមលើនូវពាក្យសុំលាឈប់ពី តួនាទី និងតំណែងប្រធាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតរបស់ ឯកឧត្តម ស៊ិក ប៊ុនហុក។

៤-យល់ព្រមនូវ សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការជ្រើសរើសបេក្ខជនប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងប្រគល់ភារកិច្ចជូនអគ្គលេខាធិការដ្ឋានរដ្ឋសភា ធ្វើសេចក្តីជូនដំណឹងជ្រើសរើសបេក្ខជន ហើយធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាវិញ។

៥-យល់ព្រមបញ្ចូលក្នុងរបៀបវារៈសម័យប្រជុំរដ្ឋសភាលើកទី៥ និងលើកទី៦ នីតិកាលទី៦ នូវៈ

៥.១ សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុន ស្មេរថេក ខូ អិលធីឌី សម្រាប់គម្រោងអភិវឌ្ឍអគ្គិសនីតង់ស្យុង៥០០គីឡូវ៉ុលពីខេត្តបាត់ដំបង ទៅកាន់ព្រំដែនកម្ពុជា-ថៃ។

៥.២ សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុន ស្មេរថេក ខូ អិលធីឌី សម្រាប់គម្រោងអភិវឌ្ឍអគ្គិសនីតង់ស្យុង៥០០គីឡូវ៉ុលពីខេត្តបាត់ដំបង ទៅកាន់ព្រំដែនកម្ពុជា-ឡាវ។

៥.៣ សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុនអគ្គិសនីវៀតណាម នៃសាធារណរដ្ឋសង្គមនិយមវៀតណាមសម្រាប់ការធានាលើការទិញថាមពលអគ្គិសនីពីប្រទេសវៀតណាម។

៥.៤ សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុនឆាយណា ណេសិនណល ហេវី ម៉ាស៊ីនណឺរី ខបភើរេសិន សម្រាប់គម្រោងអភិវឌ្ឍអគ្គិសនីស្ទឹងតាតៃ អនុភាព១៥០មេហ្គាវ៉ាត់ ខេត្តកោះកុង។

៦-យល់ព្រមលើសេចក្តីព្រាងរបាយការណ៍សកម្មភាពការងាររបស់រដ្ឋសភា ចន្លោះសម័យប្រជុំលើកទី៥ និងលើកទី៦ នីតិកាលទី៦ ដោយបានប្រគល់ភារកិច្ចដល់អគ្គលេខាធិការដ្ឋានរដ្ឋសភា បន្តបញ្ចូលសកម្មភាពការងាររបស់រដ្ឋសភា រហូតដល់ថ្ងៃបើកសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ។

ឃ/. សម័យប្រជុំ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ប្រព្រឹត្តទៅតាមប្រព័ន្ធវីដេអូ ដោយបានៈ

-ពិនិត្យរបាយការណ៍ស្តីពីលទ្ធផលនៃការទទួលពាក្យសុំឈរឈ្មោះជាបេក្ខជនប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ អនុម័តបញ្ជូនបេក្ខជនប្រធាន គ.ជ.ប ដែលដាក់ពាក្យសុំឈរឈ្មោះ ហើយដែលមាន

សំណុំបែបបទគ្រប់គ្រាន់ និងត្រឹមត្រូវតាមច្បាប់ចំនួន២រូប ទៅជូនគណបក្សនយោបាយពាក់ព័ន្ធ ដើម្បីធ្វើការជ្រើសរើសយកតែមួយរូប សម្រាប់ដាក់ជូនរដ្ឋសភាបោះឆ្នោតសម្តែងការទុកចិត្ត។

-អនុម័តប្រគល់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ជូនដល់គណៈកម្មការទី៩នៃរដ្ឋសភា សហការជាមួយគណៈកម្មការទី៥នៃរដ្ឋសភា ពិនិត្យសិក្សា ហើយធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាវិញ។

-អនុម័តប្រគល់សេចក្តីព្រាងច្បាប់ស្តីពី ការប្រកួតប្រជែង ជូនគណៈកម្មការទី៩នៃរដ្ឋសភា ពិនិត្យសិក្សា ហើយធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍វិញ។

**ង/. សម័យប្រជុំ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១** គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ប្រព្រឹត្តទៅតាមប្រព័ន្ធវីដេអូ ដោយបាន៖

១. អនុម័តសំណើសុំជ្រើសរើស **ឯកឧត្តម ប្រាជ្ញ ចន្ទ** ជាបេក្ខជនប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីដាក់ជូនសម័យប្រជុំរដ្ឋសភា លើកទី៦ នីតិកាលទី៦ បោះឆ្នោតទុកចិត្ត។

២. អនុម័តសំណើសុំទទួលស្គាល់ **ឯកឧត្តម ម៉ែន គួន** តំណាងរាស្ត្រមណ្ឌលខេត្តត្បូងឃ្មុំ ជំនួស **ឯកឧត្តម ប្រាជ្ញ ចន្ទ** ដែលបានសុំលាលែង ដើម្បីសម្រេចអំពីសុពលភាពនៃអាណត្តិ នៅក្នុងសម័យប្រជុំរដ្ឋសភា លើកទី៦ នីតិកាលទី៦។

៣. អនុម័តរបាយការណ៍ស្តីពីសកម្មភាពការងាររបស់រដ្ឋសភា ចន្លោះសម័យប្រជុំរដ្ឋសភា លើកទី៥ និងលើកទី៦ នីតិកាលទី៦។

៤. អនុម័តសមាសភាពលេខាធិការសម័យប្រជុំរដ្ឋសភា លើកទី៦ នីតិកាលទី៦នៃរដ្ឋសភា ចំនួន៣រូប។

៥. អនុម័តកាលបរិច្ឆេទ បើកសម័យប្រជុំរដ្ឋសភា លើកទី៦ នីតិកាលទី៦ នៅព្រឹកថ្ងៃ២៤ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ៨:០០នាទី ដោយមានរបៀបវារៈ ចំនួន៩ ដូចបានចែកជូនសមាជិក សមាជិការដ្ឋសភារួចហើយ។

## II. សកម្មភាពប្រជុំរដ្ឋសភាជាវិសាមញ្ញ

អនុលោមតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ រដ្ឋសភាបានកោះប្រជុំជាវិសាមញ្ញ នៅថ្ងៃសុក្រ ទី០៥ ខែមីនា ឆ្នាំ២០២១ ដើម្បីពិនិត្យ និងអនុម័ត **សេចក្តីព្រាងច្បាប់ស្តីពី វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត**។ រដ្ឋសភាជាវិសាមញ្ញ បានធ្វើការអនុម័តជាឯកច្ឆ័ន្ទនូវសេចក្តីព្រាងច្បាប់ខាងលើនេះ ដោយពុំមានសំឡេងជំទាស់ ឬអនុប្បវាទឡើយ។

## III. សកម្មភាពការទូតសភា

នៅក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភានេះ មានសកម្មភាពទំនាក់ទំនងអន្តរជាតិ តាមរយៈប្រព័ន្ធវីដេអូដែលភ្ជាប់ពីវិមានរដ្ឋសភា ទៅកាន់បណ្តាប្រទេសនានាលើពិភពលោក មានជាអាទិ៍៖

១. នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ ខ្ញុំប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម លី ចាងហ្ស៊ូ ប្រធានសភាប្រជាជនទូទាំងប្រទេស នៃសាធារណរដ្ឋប្រជាមានិតចិន បានធ្វើជាអធិបតីដ៏ខ្ពង់ខ្ពស់ ដឹកនាំកិច្ចប្រជុំស្តីពី ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងសភាប្រទេសទាំងពីរ តាមប្រព័ន្ធវីដេអូ។

ក្នុងជំនួបទ្វេភាគីនេះ សភានៃប្រទេសទាំងពីរបានថ្លែងនូវសុន្ទរកថាគន្លឹះ នៅក្នុងឱកាសបើកនៃកិច្ចប្រជុំ ដែលមានខ្លឹមសារជាអាទិ៍៖

-រដ្ឋសភាកម្ពុជា និងចិន បានគាំទ្រចំពោះសមិទ្ធផលជាច្រើន ដែលកើតចេញពីទំនាក់ទំនងដ៏ល្អរវាងប្រទេសទាំងពីរក្នុងរយៈពេល៦៣ឆ្នាំ នៃចំណងការទូតនៃប្រទេសទាំងពីរ។ ប្រធានសភាប្រទេសទាំងពីរ បានប្តេជ្ញារួមគ្នា គាំទ្រនិងថែរក្សា លើកកម្ពស់ទំនាក់ទំនងជាប្រពៃណីប្រទេសទាំងពីរ ឲ្យបានរឹងមាំយូរអង្វែង ដើម្បីតម្កល់ផលប្រយោជន៍ដល់ប្រទេស និងប្រជាជនទាំងសង្ខាង។

-ខ្ញុំប្រធានរដ្ឋសភា បានសម្តែងការពេញចិត្តយ៉ាងខ្លាំង ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលប្រទេសទាំងពីរ ក្នុងការពង្រឹងនិងពង្រីកបន្ថែមនូវកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ ជាអាទិ៍មានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងកិច្ចសហប្រតិបត្តិការស៊ីជម្រៅផ្សេងៗទៀតជាច្រើន ជាមួយនេះ ខ្ញុំក៏បានអរគុណដល់ប្រទេសចិន ដែលបានសម្រេចឧបត្ថម្ភវ៉ាក់សាំង ចំនួន១លានដុសដល់កម្ពុជា។ កម្ពុជាតែងតែប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នូវ "គោលនយោបាយចិនតែមួយ" និងគាំទ្រចំពោះកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលចិន ក្នុងកិច្ចការពារអធិបតេយ្យ និងបូរណភាពដែនដី។

បន្ទាប់មកសមភាគីទាំងពីរ បានផ្តល់វេទិកាជូនគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភា ដឹកនាំដោយ **លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី** អនុប្រធានទី២នៃរដ្ឋសភា អមដោយគណៈកម្មការជំនាញចំនួន៤ របស់រដ្ឋសភា ចំណែកគណៈប្រតិភូជាន់ខ្ពស់សភាប្រជាជនចិនតំណាងទូទាំងប្រទេស ដឹកនាំដោយ **ឯកឧត្តម ចាន់ ឈុនស៊ាន** អនុប្រធានសភាប្រជាជនចិនទូទាំងប្រទេស អមដោយគណៈកម្មការជំនាញចំនួន៤ របស់សភាប្រជាជនចិន ដើម្បីពិភាក្សាផ្លាស់ប្តូរទស្សនៈយោបល់ និងការចែករំលែកបទពិសោធន៍ជាមួយគ្នាទៅវិញទៅមក លើប្រធានបទសំខាន់ៗចំនួន៤ ដើម្បីជំរុញលើកកម្ពស់កិច្ចសហប្រតិបត្តិការសភាប្រទេសទាំងពីរឲ្យកាន់តែស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ ទាំងក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី។

២. នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២១ **ខ្ញុំប្រធានរដ្ឋសភា** បានជួបសន្ទនាការងារជាមួយ **ឯកឧត្តម វឿង ឌីញហ្វេ** (Vuong Dinh Hue) ប្រធានរដ្ឋសភាវៀតណាម តាមប្រព័ន្ធវីដេអូ ដែលភ្ជាប់ពីវិមានរដ្ឋសភាទៅកាន់រដ្ឋសភាវៀតណាម។

កិច្ចសន្ទនា ថ្នាក់ដឹកនាំរដ្ឋសភាប្រទេសទាំងពីរវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលជាច្រើននៅគ្រប់វិស័យ ដែលប្រទេសទាំងពីរសម្រេចបាន ទៅនៅស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ក្រោយកិច្ចសហប្រតិបត្តិការដ៏ល្អជាប្រពៃណី និងមិត្តភាព ដែលមានតាំងពីយូរមកហើយ និងបានសន្យារួមគ្នាក្នុងការជំរុញឲ្យសម្រេចបាននូវគ្រប់ចំនុចអាទិភាព ដែលបានចុះហត្ថលេខាកាលពីឆ្នាំ២០១៩ និងបន្តគាំទ្រគ្នាទៅវិញទៅមកលើវេទិកាអន្តរសភា ទាំងនៅក្នុងតំបន់ និងសកលលោក។

៣. នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ **លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី** អនុប្រធានទី២នៃរដ្ឋសភា បានចូលរួមកិច្ចប្រជុំការិយាល័យនយោបាយរបស់ **អាយកាប់ ICAPP** ដែលជាកិច្ចប្រជុំចង្អៀត តាមប្រព័ន្ធវីដេអូផ្សាយចេញពីសាធារណរដ្ឋកូរ៉េ។

កិច្ចប្រជុំនេះ បានអនុញ្ញាតឲ្យថ្នាក់ដឹកនាំកំពូលរបស់ **អាយកាប់** ពិភាក្សាគ្នាអំពីផែនការសកម្មភាពឆ្នាំ២០២១ និងការដឹកនាំរបស់ **អាយកាប់** ឆ្ពោះទៅអនាគត។ ជាលទ្ធផលអង្គប្រជុំ បានកំណត់យកកម្មវិធីព្រាងប្រជុំការងារចំនួន១១ចំណុច សម្រាប់ឆ្នាំ២០២១ និងពិភាក្សាបន្ថែមពីការពង្រឹងរបៀបរបបការងារប្រកបដោយបរិយាប័នជាងមុន ដោយអនុលោមតាមធម្មនុញ្ញរបស់ **អាយកាប់**។

**៤. ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី** អនុប្រធានទី២នៃរដ្ឋសភា អនុប្រធាន **អាយកាប់** ICAPP និងជាប្រធានក្រុមប្រឹក្សាវប្បធម៌អាស៊ី បានធ្វើជាសហប្រធាន ដើម្បីដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាវប្បធម៌អាស៊ីលើកទី២ ក្រោមប្រធានបទស្តីពី **"ការលើកកម្ពស់វប្បធម៌ និងនវានុវត្តន៍សម្រាប់វិបុលភាពរួមក្នុងអំឡុងពេល និងក្រោយកូវីដ-១៩"** តាមប្រព័ន្ធអ៊ីនធើណែត។

កិច្ចប្រជុំនេះមានការចូលរួមពីគណៈប្រតិភូជាន់ខ្ពស់នៅក្នុងទ្វីបអាស៊ី និងតំណាងគណបក្សនយោបាយសំខាន់ៗក្នុងក្របខណ្ឌ **អាយកាប់** ICAPP រួមជាមួយអ្នកសង្កេតការណ៍មកពីការិយាល័យអង្គការសហប្រជាជាតិសម្រាប់សេវាគម្រោង **យូអិនអូភីអេស** UNOPS វិទ្យាស្ថានចក្ខុវិស័យអាស៊ី និងស្ថាប័នមួយចំនួនទៀត។

**៥. នៅថ្ងៃទី១៩ ដល់ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៉ែន បញ្ញា** ប្រធានគណៈកម្មការទី៦នៃរដ្ឋសភា និងជាប្រធានក្រុមសភាជាតិកម្ពុជា **អាប៉េអេហ្វ** APF បានដឹកនាំគណៈប្រតិភូសភា ចូលរួមកិច្ចប្រជុំមហាសន្និបាត អាប៉េអេហ្វ APF លើកទី៤៦ ដែលប្រព្រឹត្តឡើងតាមប្រព័ន្ធវីដេអូ ភ្ជាប់ពីវិមានព្រឹទ្ធសភា និងរដ្ឋសភា ទៅកាន់ទីក្រុងប៉ារីស ប្រទេសបារាំង។

នៅក្នុងអំឡុងពេលនៃមហាសន្និបាតនេះ ក៏មានបែងចែកកិច្ចប្រជុំគណៈកម្មការនានា រួមមាន៖ -កិច្ចប្រជុំគណៈកម្មការស្ត្រី -កិច្ចប្រជុំគណៈកម្មការអប់រំ -កិច្ចប្រជុំគណៈកម្មការអចិន្ត្រៃយ៍ -កិច្ចប្រជុំគណៈកម្មការនយោបាយ -កិច្ចប្រជុំគណៈកម្មការអភិវឌ្ឍន៍ និង -កិច្ចប្រជុំគណៈកម្មការកិច្ចការសភា ជាដើម។

សារសំខាន់នៃកិច្ចប្រជុំមហាសន្និបាតនេះ គឺផ្តោតលើការយកចិត្តទុកដាក់ខ្ពស់ លើការរាតត្បាតកូវីដ-១៩ ជាសកល និងបានអនុម័តនូវសេចក្តីសម្រេចមួយស្តីពី បញ្ហាកូវីដ-១៩ ក្នុងចំណោមសេចក្តីសម្រេចទាំង១០ ដោយបានអំពាវនាវដល់សមាជិក អាប៉េអេហ្វ ទាំងអស់ឲ្យប្តេជ្ញាចិត្តធ្វើឲ្យវ៉ាក់សាំងកូវីដ ក្លាយជា **"សម្បត្តិរួមរបស់ពិភពលោក"**។

**៦. នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តម អ៊ុក ដាមរី** សមាជិក និង **លោកជំទាវ ឯម ប៉ុណ្ណា** សមាជិការដ្ឋសភាក្រុមជាតិ **ហ្គោផាកកម្ពុជា** GOPAC បានចូលរួមកិច្ចប្រជុំតាមប្រព័ន្ធវីដេអូ ដែលភ្ជាប់ពីវិមានរដ្ឋសភា ទៅកាន់ទីក្រុងហ្សាកាតា នៃប្រទេសឥណ្ឌូនេស៊ី ក្រោមប្រធានបទ កិច្ចប្រជុំពិសេសមហាសន្និបាតអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ យូអិនហ្គេស UNGASS ២០២១ តើសមាជិកសភាមានតួនាទីអ្វីខ្លះ?។

កិច្ចប្រជុំនេះ បានអនុម័តនូវរបៀបវារៈចំនួន៦ ចំពោះការចូលជាសមាជិក ភាគីកម្ពុជាបានរក្សាជំហរតាមគោលការណ៍ដ៏ខ្ពង់ខ្ពស់របស់ **ខ្ញុំប្រធានរដ្ឋសភា** ដោយសារយោងតាមបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ជាហេតុដែលកញ្ចប់ថវិកាកម្ពុជានូវមានកម្រិតក្នុងការបង់វិភាគទាន។

**៧.នៅថ្ងៃទី១៧ ដល់ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តម ឈាង វុន** ប្រធានគណៈកម្មការទី៥នៃរដ្ឋសភា និងជាប្រធានក្រុមសភាជាតិកម្ពុជា **អាយភីយូ** IPU បានដឹកនាំគណៈប្រតិភូសភាកម្ពុជា ចូលរួមសវនាការប្រចាំរបស់សភានៅអង្គការសហប្រជាជាតិឆ្នាំ២០២១ ក្រោមប្រធានបទស្តីពី **"ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ដើម្បីស្តារឡើងវិញនូវទំនុកចិត្តលើរដ្ឋាភិបាល និងធ្វើឲ្យប្រសើរឡើងវិញនូវទស្សនវិស័យនៃការអភិវឌ្ឍ"**តាមប្រព័ន្ធវីដេអូដែលភ្ជាប់ពីវិមានរដ្ឋសភា ទៅកាន់ទីស្នាក់ការអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក។

សវនាការនេះ គឺជាការបង្ហាញពីតួនាទីពិសេសរបស់សភា ក្នុងការពាំនាំ និងរៀបចំដាក់បញ្ចូលនូវរាល់ខ្លឹមសារនៃសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិទៅក្នុងច្បាប់ជាតិ ដើម្បីបម្រើផលប្រយោជន៍សម្រាប់ប្រជាជាតិ និងប្រជាជនទាំងអស់គ្នា។

៨.នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ **ឯកឧត្តម អ៊ុក ដាមរី** សមាជិកគណៈកម្មការទី១០នៃរដ្ឋសភា និងជាសមាជិកក្រុមរដ្ឋសភាជាតិអាយប៉ា-កម្ពុជា រួមជាមួយ **ឯកឧត្តម ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥នៃព្រឹទ្ធសភា និងមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានសភាកម្ពុជា បានចូលរួម **"កិច្ចប្រជុំរវាងសភាសមាជិកអាយប៉ា និងសភានៃព្រះរាជាណាចក្រណ័រវេ"** តាមប្រព័ន្ធវីដេអូ ដែលភ្ជាប់ពីវិមានរដ្ឋសភា ទៅកាន់ទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។ កិច្ចប្រជុំនេះមានគោលបំណង ដើម្បីឲ្យសភាណ័រវេ ណែនាំសមាជិករបស់ខ្លួនឲ្យមានការប្រាស្រ័យទាក់ទងគ្នា ជាមួយសភានៃប្រទេសសមាជិកអាយប៉ាទាំង១០ ក្រោយពីសភាណ័រវេ បានក្លាយជាសមាជិកអង្កេតការណ៍របស់អាយប៉ា។

៩. ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ **លោកជំទាវ ឡោក ខេង** ប្រធានគណៈកម្មការទី៨នៃរដ្ឋសភា បានដឹកនាំប្រតិភូរដ្ឋសភា និងមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ចូលរួមសិក្ខាសាលាស្តីពី **"ឆន្ទៈនយោបាយទៅជាច្បាប់៖ ការលើកកម្ពស់ការគ្របដណ្តប់សុខភាពជាសកលនៅតំបន់អាហ្វ្រិក និងអាស៊ីប៉ាស៊ីហ្វិក"** តាមប្រព័ន្ធវីដេអូ ដែលតភ្ជាប់ពីវិមានរដ្ឋសភា ទៅកាន់ទីក្រុងហ្សឺណែវ ប្រទេសស្វីស។

១០. ថ្ងៃទី០៩ ខែមីនា ឆ្នាំ ២០២១ គណៈប្រតិភូសភាកម្ពុជា ដឹកនាំដោយ **លោកជំទាវ ឡោក ខេង** ប្រធានគណៈកម្មការទី៨ នៃរដ្ឋសភា បានចូលរួមកិច្ចប្រជុំស្តីពី **"ស្ត្រី និងសេដ្ឋកិច្ចគ្រួសារជាស្នូល"** (គោលនយោបាយ កម្មវិធី និងបទពិសោធន៍ជោគជ័យ÷ការត្រួតពិនិត្យច្បាប់ ការផ្តល់សិទ្ធិអំណាចដល់គ្រួសារ និងសក្តានុពលចលនាសេដ្ឋកិច្ច) ដែលមានការចូលរួមដោយក្រុមសមាជិកសភាស្ត្រី និងគ្រួសារ(Woman and Family Faction) នៃសភាអ៊ីស្លាម និងក្រុមសមាជិកសភានៃសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ ក្នុងសន្និបាតសភាអាស៊ី អេភីអេ (APA) និងតំណាងនៃបណ្តាសភាតំបន់អាស៊ី អង្គការ និងមជ្ឈមណ្ឌលទាក់ទងនឹងស្ត្រី និងគ្រួសារ ដោយមានតំណាង ២១ប្រទេសចូលរួម តាមរយៈប្រព័ន្ធវីដេអូ ដែលតភ្ជាប់ពីវិមានរដ្ឋសភា ទៅកាន់ទីក្រុងតេអ៊ីរ៉ង់ (Tehran) ប្រទេសអ៊ីរ៉ង់ (Iran)។

១១.ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ **លោកជំទាវ ឡោក ខេង** ប្រធានគណៈកម្មការទី៨នៃរដ្ឋសភា បានចូលរួមសិក្ខាសាលាតាមអនឡាញ ស្តីពីផលប៉ះពាល់នៃរោគរាតត្បាតកូវីដ-១៩ លើសមភាពយេនឌ័រ។ ក្នុងនាមរដ្ឋសភា លោកជំទាវ បានធ្វើការចែករំលែកនូវមតិយោបល់មួយចំនួនដល់អង្គសិក្ខាសាលាសម្រាប់ពិចារណា និងផ្លាស់ប្តូរបទពិសោធន៍រវាងសមាជិកសភាទាំងអស់ ដោយស្នើសមាជិកសភាដែលមានវត្តមានក្នុងអង្គសិក្ខាសាលាត្រូវវិភាជន៍ធនធានបន្ថែម ដើម្បីគាំទ្រដល់ស្ត្រី ជាពិសេសក្នុងវិស័យសុខាភិបាល អប់រំ និងអភិវឌ្ឍន៍ជំនាញ។

១២.ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១ គណៈប្រតិភូសភាកម្ពុជា ដឹកនាំដោយ **ឯកឧត្តម អ៊ុក ដាមរី តំណាងរាស្ត្រមណ្ឌលខេត្តកណ្តាល និងជាសមាជិកក្រុមរដ្ឋសភាជាតិ អាយប៉ា** (AIPA)-កម្ពុជា រួមជាមួយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា បានចូលរួមកិច្ចប្រជុំក្រុមការងារជំនាញ Ad-Hoc Working Group (AIPA) តាមប្រព័ន្ធវីដេអូ ដែលភ្ជាប់ពីវិមានរដ្ឋសភា ទៅកាន់រដ្ឋសភា ប្រទេសប្រ៊ុយណេ។

១៣.ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ គណៈប្រតិភូសភាកម្ពុជា រួមមាន **ឯកឧត្តម សួស យ៉ារ៉ា** អនុប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃរដ្ឋសភា **ឯកឧត្តម ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥នៃព្រឹទ្ធសភា **ឯកឧត្តម ងួន សុជាតិ** សមាជិកគណៈកម្មការទី៥

នៃរដ្ឋសភា ដោយមានការចូលរួមពីមន្ត្រីជំនាញ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព នៃសភាតំបន់អាស៊ី (APA) តាមរយៈប្រព័ន្ធវីដេអូ ដែលភ្ជាប់ពីវិមានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ទៅកាន់ទីក្រុងម៉ាណាម៉ា ព្រះរាជាណាចក្របារ៉ែន។

**១៤.ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១** មានកិច្ចប្រជុំដាច់ដោយឡែកពីគ្នា ចំនួន៤ រួមមាន៖

+**លោកជំទាវ** ឯម ប៉ុណ្ណា អនុប្រធានគណៈកម្មការទី១ **ឯកឧត្តម យឹម លាត** សមាជិកគណៈកម្មការទី២ **ឯកឧត្តម ឡុង បុន្នី** សមាជិកគណៈកម្មការទី៤ **និង លោកជំទាវ ម៉ាណ ណាវី** សមាជិការដ្ឋសភា បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃមហាសន្និបាតសហភាពអន្តរសភា លើកទី១៤២ អាយភីយូ ដឹកនាំដោយ **ឯកឧត្តម យ៉ង់ សែម** ប្រធានគណៈកម្មការទី១នៃព្រឹទ្ធសភា តាមរយៈប្រព័ន្ធវីដេអូ នៅវិមានព្រឹទ្ធសភា ដែលផ្សាយចេញពីទីក្រុងហ្សឺណែវ ប្រទេសស្វីស ដោយមានប្រទេសជាសមាជិកចូលរួម សរុបចំនួន១៣៥ប្រទេស។

+**ឯកឧត្តម ហ៊ុន ម៉ានី** ប្រធានគណៈកម្មការទី៧នៃរដ្ឋសភា បានដឹកនាំគណៈប្រតិភូសមាជិកសភាវ័យក្មេងនៃរដ្ឋសភាកម្ពុជា រួមមាន **ឯកឧត្តម សួស យ៉ារ៉ា ឯកឧត្តម កែវ ពិសិដ្ឋ ឯកឧត្តម ដុំ យុហៀង ឯកឧត្តម សន សារ៉ាណា ឯកឧត្តម ជាម ប៉េអា ឯកឧត្តម ងួន សុជាតិ ឯកឧត្តម យឹម លាត ឯកឧត្តម យុត ចាន់ដារ៉ា លោកជំទាវ ម៉ាណ ណាវី ឯកឧត្តម សុខ សូកេន** ប្រជុំជាមួយគណៈប្រតិភូវ័យក្មេងសភាតំណាងប្រជាជនចិនទូទាំងប្រទេស នៅវិមានរដ្ឋសភា។

កិច្ចប្រជុំនេះបានពិភាក្សា និងចែករំលែកបទអន្តរាគមន៍ក្រោមប្រធានបទចំនួន៣ ដែលជាការឆ្លុះបញ្ចាំងនូវភាពរឹងមាំនៃចំណងមិត្តភាពកម្ពុជា-ចិន ក្នុងការកសាងសហគមន៍ជោគវាសនារួមដែលមានលក្ខណៈយុទ្ធសាស្ត្រ ជាពិសេសរវាងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងសភាតំណាងប្រជាជនចិនទូទាំងប្រទេស ដែលថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ បានប្រសិទ្ធនាមថា **"ចំណងមិត្តភាពដែកថែប"** និងបានបង្កើត **"ទំនាក់ទំនងកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ"** ។ តាមរយៈកិច្ចប្រជុំនេះ គណៈប្រតិភូបាន ពិភាក្សាផ្លាស់ប្តូរយោបល់ បទពិសោធន៍ និងទស្សនៈនៃការចូលរួមផ្ទាល់ជាមួយបក្ស និងរដ្ឋាភិបាលនៅក្នុងកិច្ចការជាតិ និងអន្តរជាតិ ក៏ដូចជាទស្សនវិស័យឆ្ពោះទៅអនាគតនៃទំនាក់ទំនងទ្វេភាគីរវាងប្រទេសយើងទាំងពីរ ជាពិសេសក្នុងក្របខណ្ឌសមាជិកសភាវ័យក្មេង ដើម្បីកសាងសហគមន៍ជោគវាសនារួម ដែលមានលក្ខណៈពិសេសគឺពេញលេញ ពិតប្រាកដ កម្រិតខ្ពស់ និងស៊ីជម្រៅ។

+**លោកជំទាវ ឡោក ខេង** ប្រធានគណៈកម្មការទី៨នៃរដ្ឋសភា និងជាហេរញ្ញិក AFPPD និងជាសមាជិកា CAPPD និង **ឯកឧត្តម អ៊ុក ដាមរី** សមាជិកគណៈកម្មការទី១០នៃរដ្ឋសភា និងជាអគ្គលេខាធិការCAPPD ព្រមទាំងមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានរដ្ឋសភាកម្ពុជា បានចូលរួមមហាសន្និបាតប្រចាំឆ្នាំ នៃវេទិកាសមាជិកសភាអាស៊ីដើម្បីប្រជាជន និងការអភិវឌ្ឍ(AFPPD) តាមរយៈប្រព័ន្ធវីដេអូ ដែលតភ្ជាប់ពីវិមានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាទៅកាន់ទីក្រុងតូក្យូ ប្រទេសជប៉ុន។

+**ឯកឧត្តម ហ៊ូ ស្រ៊ី** អនុប្រធានគណៈកម្មការទី៣នៃរដ្ឋសភា និងជាសមាជិកក្រុមរដ្ឋសភាជាតិអាយប៉ា-កម្ពុជា និង **ឯកឧត្តម ទី សុគន្ធ** សមាជិកគណៈកម្មការ ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី៤ របស់ក្រុមប្រឹក្សាពិគ្រោះយោបល់ (អាយប៉ា) ស្តីពីគ្រោះថ្នាក់គ្រឿងញៀន (AIPACODD) តាមរយៈប្រព័ន្ធវីដេអូ ដែលផ្សាយចេញ

ពីប្រទេសប្រ៊ុយណេ ក្រោមប្រធានបទ ៖ "ការយកឈ្នះ នឹងបញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងការទទួលខុសត្រូវ ដើម្បីឈាន ទៅរកអាស៊ានគ្មាន គ្រឿងញៀន"។

**១៥. ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១ ឯកឧត្តម អ៊ុក ដាមរី** សមាជិកគណៈកម្មការទី១០នៃរដ្ឋសភា និងជាអគ្គលេខាធិការ **ស៊ីអេភីភីឌី CAPPD** រួមជាមួយ **ឯកឧត្តម ពេជ្រ ជីវន្ត** សមាជិកគណៈកម្មការទី៨នៃរដ្ឋសភា ព្រមទាំងមន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការកិច្ចការអេចិន្ត្រៃយ៍ស្ត្រី និងសមភាពយេនឌ័រ នៃវេទិកាសមាជិកសភាអាស៊ី ដើម្បីប្រជាពលរដ្ឋ និងការអភិវឌ្ឍ ក្រោមប្រធានបទ **"តម្រោយផ្លូវដើម្បីបញ្ចប់អាពាហ៍ពិពាហ៍កុមារ"** តាមរយៈប្រព័ន្ធវីដេអូ ដែលផ្សាយចេញពីទីក្រុងតូក្យូ ប្រទេសជប៉ុន។

**១៦. ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ ឯកឧត្តម អ៊ុក ដាមរី** បានដឹកនាំគណៈប្រតិភូសភាកម្ពុជា ចូលរួមកិច្ចប្រជុំជាមួយក្រុមការងារជំនាញ (Ad-Hoc Working Group) លើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី **"ការផ្លាស់ប្តូរលេខាធិការដ្ឋានអាយប៉ា"** តាមប្រព័ន្ធវីដេអូដែលផ្សាយចេញពីទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ីមកកាន់រដ្ឋសភាកម្ពុជា។

**១៧. ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី** អនុប្រធានទី២នៃរដ្ឋសភា បានចូលរួមកិច្ចប្រជុំជាមួយតំណាងនៃបណ្តាប្រទេសអាស៊ាន ក្រោមប្រធានបទ **"តួនាទីរបស់កម្លាំងនយោបាយដែលមានការទទួលខុសត្រូវ ក្នុងការកសាងទំនាក់ទំនងវប្បធម៌គ្នាទៅវិញទៅមក ប្រកបដោយប្រសិទ្ធភាព ក្នុងក្របខ័ណ្ឌនៃព្រឹត្តិការណ៍ម៉ារ៉ាតុនវប្បធម៌ ពីអាត្លង់ទិករហូតដល់មហាសមុទ្រប៉ាស៊ីហ្វិក"** ដែលបានប្រព្រឹត្តតាមប្រព័ន្ធវីដេអូ ផ្សាយចេញពីសហព័ន្ធរុស្ស៊ី។

**១៨.ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១** កិច្ចប្រជុំតាមរយៈប្រព័ន្ធវីដេអូ ចំនួន៣ ដាច់ដោយឡែកពីគ្នា រួមមាន៖

+**លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី** អនុប្រធានទី២នៃរដ្ឋសភា ត្រូវបានចូលរួមជាភ្ញៀវឥស្សរជនជាន់ខ្ពស់ តំណាងឱ្យគណបក្សប្រជាជនកម្ពុជា ក្នុងកិច្ចសន្ទនានយោបាយពិសេស តាមប្រព័ន្ធវីដេអូក្រោមចំណងជើងថា **"រឿងរ៉ាវរបស់គណបក្សកុម្មុយនីស្តចិន៖សមិទ្ធផលរបស់ក្រុងសៀងហៃក្នុងការអនុវត្តគំនិត ស៊ី ជីនភីង ស្តីពីសង្គមនិយមមានលក្ខណៈពិសេសចិនសម្រាប់យុគ្គសម័យថ្មី"** ដោយផ្តោតលើប្រធានបទ **"ធ្វើឱ្យសុបិន្តក្លាយជាការពិត ចែករំលែកភាពអស្ចារ្យ"** ដែលប្រព្រឹត្តធ្វើឡើងនៅទីក្រុងសៀងហៃ សាធារណរដ្ឋប្រជាមានិតចិន ។

+**ឯកឧត្តម នឹម ច័ន្ទតារា** បានដឹកនាំគណៈប្រតិភូអាយប៉ាកម្ពុជា រួមមាន **ឯកឧត្តម អ៊ុក ដាមរី** និង **លោកជំទាវ ម៉ក់ វណ្ណស៊ីថា** ព្រមទាំងមន្ត្រីជំនាញ ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ របស់ក្រុមអ្នកនយោបាយអាយប៉ា លើកទី១២ (12-AIPA Caucus) ដើម្បីពិភាក្សាលើប្រធានបទចំនួន២ គឺ "ភាពធន់នៃសង្វាក់ផ្គត់ផ្គង់ និងការលើកកម្ពស់ការតភ្ជាប់ពាណិជ្ជកម្ម" និង"ការអនុវត្តសេចក្តីសម្រេចនៃមហាសន្និបាតអន្តរសភាអាស៊ាន លើកទី៤១" តាមប្រព័ន្ធវីដេអូ ផ្សាយចេញពីប្រទេសសិង្ហបូរី។

+**ឯកឧត្តម ច័ន្ទ សុផល** អនុប្រធានគណៈកម្មការទី៤នៃរដ្ឋសភា បានដឹកនាំគណៈប្រតិភូរដ្ឋសភា រួមមាន **ឯកឧត្តម ងួន សុជាតិ** និង **ឯកឧត្តម ជុំ យុហៀន** សមាជិកគណៈកម្មការទី៥នៃរដ្ឋសភា ចូលរួមពិធីបើកកិច្ចប្រជុំរបស់ការិយាល័យអង្គការសហប្រជាជាតិប្រឆាំងភេរវកម្ម (United Nations Office of Counter-Terrorism-UNOCT) ស្តីពីការចូលរួមរបស់សភាក្នុងការប្រយុទ្ធប្រឆាំងភេរវកម្ម តាមរយៈប្រព័ន្ធវីដេអូ ដែលផ្សាយចេញពីទីក្រុងដូហា ប្រទេសកាតា។

**១៩. ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ ឯកឧត្តម ឈាង វុន** ប្រធានគណៈកម្មទី៥នៃរដ្ឋសភា បានដឹកនាំគណៈប្រតិភូ រួមមាន **ឯកឧត្តម សួស យ៉ារ៉ា ឯកឧត្តម នឹម ច័ន្ទតារា ឯកឧត្តម ងួន សុជាតិ ឯកឧត្តម ទី សុគន្ធ**

**សមាជិក លោកជំទាវ កុប ម៉ារីយ៉ាស ឯកឧត្តម យិន គីមស៊ាន និង ឯកឧត្តម ជុំ យុហៀន** ចូលរួមកិច្ចប្រជុំត្រៀមរៀបចំសន្និសីទលើកទី៨នៃគណៈកម្មការកិច្ចការបរទេសនៃរដ្ឋសភា កម្ពុជា-ឡាវ និងវៀតណាម (CLV) តាមប្រព័ន្ធវីដេអូ ទៅលើរបៀបវារៈ ចំនួន៤។

## IV. សកម្មភាពក្នុងអំឡុងពេលការរីករាលដាល ឆ្លងចូលសហគមន៍នៃជំងឺកូវីដ-១៩ ជាពិសេសព្រឹត្តិការណ៍ ២០ កុម្ភៈ

ក្នុងអំឡុងពេលនៃផ្ទុះការរាលដាលជំងឺកូវីដ-១៩ ជាពិសេសចាប់ពីព្រឹត្តិការណ៍ ២០កុម្ភៈ មកដល់បច្ចុប្បន្ន ថ្នាក់ដឹកនាំរដ្ឋសភា ក៏ដូចសមាជិក សមាជិការដ្ឋសភាទាំងអស់ បានឯកភាព និងគាំទ្រវិធានការនានារបស់រាជរដ្ឋាភិបាល ក្នុងទិសដៅដើម្បីទប់ស្កាត់ការរីករាលដាលនេះ មានជាអាទិ៍៖ បានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពរួមមាន៖

-ការគោរពតាមចំណាត់ការនានាដែលរាជរដ្ឋាភិបាលចាត់ឡើង ជាអាទិ៍ក្នុងការបិទខ្ទប់រាជធានីភ្នំពេញ **ពីថ្ងៃ១៤ ខែមេសា ឆ្នាំ២០២១ ដល់ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១។**

-មន្ត្រីរាជការ ព្រមទាំងសមាជិក សមាជិការដ្ឋសភាទាំងអស់ សុទ្ធតែបានចូលរួមចាក់វ៉ាក់សាំងទាំង៣ប្រភេទបានគ្រប់ៗគ្នា ចំនួន២លើករួមមកហើយ។

-ទោះបីមានការបិទខ្ទប់ តំណាងរាស្ត្រមួយចំនួនបានចេញទៅតាមមូលដ្ឋានរបស់ខ្លួន ដោះស្រាយការខ្វះខាតដល់ប្រជាពលរដ្ឋនៅតាមមណ្ឌលរៀងៗខ្លួន។

-នៅក្នុងតំបន់បិទខ្ទប់នៅ រាជធានីភ្នំពេញ និងខេត្តកណ្តាល សមាជិក សមាជិការដ្ឋសភាជាច្រើនរូប បានចូលរួមជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល ជាអាទិ៍៖ ចុះពន្យល់ប្រជាពលរដ្ឋ និងការជួយផ្តល់ម្ហូបអាហារជូនប្រជាជន តាមរយៈអាជ្ញាធរក្រុង ខណ្ឌ សង្កាត់។

-**ឯកឧត្តម ហ៊ុន ម៉ានី** ប្រធានគណៈកម្មការទី៧នៃរដ្ឋសភា បានចូលរួមចំណែកយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាល ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំង និងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ដោយ បានរៀបចំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចំនួន២ក្រុម គឺ ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត **ឯកឧត្តម ហ៊ុន ម៉ានី** និងសម្ព័ន្ធគ្រូពេទ្យស្ម័គ្រចិត្តសហភាពសហព័ន្ធយុវជនកម្ពុជា សរុបចំនួន៩៩៩នាក់ ចូលរួមសហការជាមួយគណៈកម្មការចំពោះកិច្ច និងមន្ត្រីសុខាភិបាល ព្រមទាំងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ក្នុងយុទ្ធនាការចាក់វ៉ាក់សាំងនៅទូទាំងប្រទេស ដោយចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២១ រហូតដល់បច្ចុប្បន្ន ក្នុងនោះបាន និងកំពុងបន្តចុះប្រតិបត្តិការចាក់វ៉ាក់សាំងតាមស្ថាប័ន និងអង្គភាព សរុបចំនួន២៨ស្ថាប័ន និង១២មណ្ឌល នៅក្នុងរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្តបានចំនួន៣ខេត្ត សរុបចំនួន៨មណ្ឌល និងបានបញ្ជូនក្រុមគ្រូពេទ្យស្ម័គ្រចិត្តចំនួន៣ក្រុម ចូលរួមក្នុងប្រតិបត្តិការពិនិត្យព្យាបាលអ្នកជំងឺកូវីដ-១៩ នៅមណ្ឌលព្យាបាលជំងឺកូវីដ-១៩សែនសុខ។

-ចំពោះសកម្មភាពទាំងឡាយដូចមានរៀបរាប់ខាងលើ ព្រមទាំងសកម្មភាពពាក់ព័ន្ធ និងការចូលរួមរបស់សមាជិក សមាជិការដ្ឋសភា ក្នុងការបង្កា ទប់ស្កាត់ ការចាក់វ៉ាក់សាំងប្រឆាំងមេរោគកូវីដ-១៩ ដទៃទៀតក្រោយការបិទខ្ទប់ក្រុងភ្នំពេញ និងខេត្តកណ្តាល មានរៀបរាប់នៅក្នុងរបាយការណ៍លម្អិត ចំនួន២៨០ទំព័រ ដូចបានចែកជូនរួចហើយ។

## V. សកម្មភាពថ្នាក់ដឹកនាំរដ្ឋសភា

### ១.សកម្មភាព ខ្ញុំប្រធានរដ្ឋសភា

ក្នុងនាមប្រធានរដ្ឋសភា និងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ក្រៅពីការដឹកនាំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ចំនួន៥លើក ប្រជុំរដ្ឋសភាជាវិសាមញ្ញ ចំនួន១លើក នៅចន្លោះសម័យប្រជុំលើកទី៥ និងលើកទី៦ នីតិកាលទី៦ នេះ ខ្ញុំបានចុះជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ មន្ត្រីរាជការ និងប្រជាពលរដ្ឋក្នុងខេត្តត្បូងឃ្មុំ និងបានបំពេញការងារផ្សេងទៀត មានជាអាទិ៍៖

ក/.សកម្មភាពដឹកនាំកិច្ចប្រជុំ និងចូលរួមកម្មវិធីផ្សេងៗ រួមមាន៖

-ដឹកនាំបើកកិច្ចប្រជុំ ជាមួយ **ឯកឧត្តម លី ចាងហ្សូ** ប្រធានសភាប្រជាជនចិនទូទាំងប្រទេស តាមប្រព័ន្ធវីដេអូ នៅវិមានរដ្ឋសភា។

-ដឹកនាំកិច្ចប្រជុំបូកសរុបការងារផ្សេងៗ នៅខេត្តត្បូងឃ្មុំ។

-ពិធីបញ្ចុះបឋមសិលាសាងសង់អគារសិក្សាថ្មីមួយខ្នងពីរជាន់ ស្មើនឹង១២បន្ទប់ ជូនដល់ **វិទ្យាល័យសម្តេចចក្រី ហេង សំរិន អន្លង់ជ្រៃ** ស្ថិតនៅភូមិអន្លង់ជ្រៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

-បានទទួលការចាក់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩ របស់ក្រុមហ៊ុនអាស្ត្រាហ្សេនីកា (Astra zeneca) ទាំង២លើករួចរាល់។

-បានផ្តល់អំណោយជាស្បៀងអាហារ មានអង្ករ គ្រឿងឧបភោគបរិភោគ រួមនឹង ថវិកាដល់រដ្ឋបាលរាជធានីភ្នំពេញ សម្រាប់ចែកជូនប្រជាពលរដ្ឋ ដែលជួបការខ្វះខាតនៅក្នុងពេលកំពុងអនុវត្តវិធានការការពារ ទប់ស្កាត់ជំងឺកូវីដ-១៩។

-បានចុះពិនិត្យដំណើរការសាងសង់អគារសិក្សាមួយខ្នង២ជាន់ មាន១២បន្ទប់ ក្នុង **វិទ្យាល័យសម្តេចចក្រី ហេង សំរិន អន្លង់ជ្រៃ** ស្ថិតនៅក្នុងភូមិអន្លង់ជ្រៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

-ដឹកនាំគណៈប្រតិភូរដ្ឋសភា ប្រជុំទ្វេភាគីតាមរយៈប្រព័ន្ធវីដេអូ ជាមួយ **ឯកឧត្តមប្រធានរដ្ឋសភាវៀតណាម**។

ខ/.សកម្មភាពទទួលជួបសវនាការ និងសម្តែងការគួរសម ជាមួយឯកអគ្គរដ្ឋទូតប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលទើបនឹងតែងថ្មី រួមមាន៖

-**លោកជំទាវ ដេវីយ៉ានី ឧត្តាំ ខូប្រាហ្គាដ** H.E Devyani Uttam Khobragade ឯកអគ្គរដ្ឋទូតសាធារណរដ្ឋឥណ្ឌា។

-**លោកជំទាវ ម៉ារៀ អាមីលីតា អាគីណូ** H.E Mrs. Maria Amelita C. Aquino ឯកអគ្គរដ្ឋទូតសាធារណរដ្ឋហ្វីលីពីន។

-**លោកជំទាវ ទេវ ឡាយឆេង** H.E Mrs. Teo Lay Cheng ឯកអគ្គរដ្ឋទូតសិង្ហបុរី។

### ២.សកម្មភាព ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ខួន សុទ្ធារិទ្ធ អនុប្រធានទី១ នៃរដ្ឋសភា

នៅចន្លោះសម័យប្រជុំរដ្ឋសភាលើកទី៥ និងលើកទី៦ នីតិកាលទី៦នេះ ឯកឧត្តមបានចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ចំនួន៥លើក ប្រជុំរដ្ឋសភាជាវិសាមញ្ញ ចំនួន១លើក និងបានបំពេញការងារផ្សេងទៀត រួមមាន៖

-ធ្វើជាអធិបតីក្នុងកិច្ចប្រជុំ ចំនួន៥លើក ជាមួយ ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា មណ្ឌលខេត្តកំពង់ធំ គណៈអភិបាល-ក្រុមប្រឹក្សាខេត្ត គណៈអភិបាលស្រុក -ក្រុមប្រឹក្សាស្រុក ក្នុងនោះ ៖ -លើកទី១ជាមួយ ស្រុកស្ទោង និងស្រុកកំពង់ស្វាយ -លើកទី២ជាមួយ ស្រុកបារាយណ៍ និង ក្រុងតាំងគោក -លើកទី៣ជាមួយ ស្រុកប្រាសាទបល្ល័ង្គ និងក្រុងស្ទឹងសែន និង-លើកទី៤ជាមួយ ស្រុកសណ្ដាន់ និងស្រុកប្រាសាទសំបូរ និង-លើកទី៥ជាមួយ ស្រុកសន្ទុក របស់ខេត្តកំពង់ធំ ដើម្បីស្វែងយល់ពីស្ថានភាពសន្តិសុខ សណ្តាប់ធ្នាប់ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

-ធ្វើជាអធិបតីក្នុងកិច្ចប្រជុំ ចំនួន១១លើក ជាមួយ ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា មណ្ឌលខេត្តកំពង់ធំ គណៈអភិបាលខេត្ត-ក្រុមប្រឹក្សាខេត្ត គណៈអភិបាលស្រុក -ក្រុមប្រឹក្សាស្រុក -ក្រុងទាំង៩របស់ខេត្តកំពង់ធំ ដើម្បីស្វែងយល់ពីស្ថានភាពសន្តិសុខសណ្តាប់ធ្នាប់ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

-ដឹកនាំកិច្ចប្រជុំគណៈកម្មការរៀបចំកិច្ចប្រជុំ អាសិប១១ ASEP11 ដើម្បីពិនិត្យពិភាក្សាលើការងារ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប លើកទី១១ នាពេលខាងមុខ ដែលសភាកម្ពុជានឹងត្រូវធ្វើជាម្ចាស់ផ្ទះ។

-ចុះសួរសុខទុក្ខ និងនាំយកនូវអំណោយ ផ្តល់ជូនប្រជាពលរដ្ឋដែលរងគ្រោះដោយអគ្គិភ័យឆេះផ្ទះ ចំនួន៣គ្រួសារ រស់នៅក្នុងភូមិក្រសាំងជ្រំជើង ឃុំសំព្រោច ស្រុកស្ទោង ខេត្តកំពង់ធំ នឹងសាងសង់ផ្ទះថ្មីជូនចំនួន ៣ខ្នងឡើងវិញ។

-ជួបប្រជុំការងារ និងសំណេះសំណាល សួរសុខទុក្ខជាមួយ លោកតាព្រឹទ្ធាចារ្យ តំណាងមកពីឃុំទាំង១៨ និង លោក លោកស្រីជាតំណាង ក្នុងស្រុកបារាយណ៍ និង ស្រុកតាំងគោក ចំនួន២លើក ដើម្បីស្វែងយល់អំពីសភាពការណ៍ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការងារសេដ្ឋកិច្ច ជីវភាពរស់នៅរបស់ប្រជាជន។

-ជួបសំណេះសំណាលសួរសុខទុក្ខ ព្រះចៅអធិការ និងគណៈកម្មការ វត្តកំពង់ពោន ហៅ វត្តបាក់ស្នា ស្ថិតនៅក្នុងភូមិបាក់ស្នា ឃុំបាក់ស្នា ស្រុកបារាយណ៍ ខេត្តកំពង់ធំ និងបានប្រគេនបច្ច័យ ដើម្បីចូលរួមកសាងសាលាឆាន់ តាមការបិណ្ឌបាត និងស្នើសុំ។

-ចុះពិនិត្យមើលដំណើរការសាងសង់ សាកលវិទ្យាល័យ « **តេជោ សែន** » កំពង់ធំ ស្ថិតនៅភូមិថ្នល់បែក ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។

-បានទទួលការចាក់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩ របស់ក្រុមហ៊ុនអាស្ត្រាហ្សេនីកា (Astrazeneca) ចំនួន២លើករួចរាល់។

-បានចាត់ឲ្យខុទ្ទកាល័យ នាំយកថវិកា និងគ្រឿងឧបភោគ បរិភោគមួយចំនួន ជូនដល់រដ្ឋបាលខេត្តកំពង់ធំ ដើម្បីគាំទ្រក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ និងដោះស្រាយជីវភាពទុកលំបាកប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដែលកំពុងធ្វើចត្តាឡីស័ក នៅក្នុងខេត្តកំពង់ធំ។

-បានដឹកនាំ ឯកឧត្តម លោកជំទាវ ជាប្រធាន អនុប្រធាន និងសមាជិក សមាជិកានៃគណៈកម្មការចំពោះកិច្ច និងគណៈកម្មការប្រតិបត្តិ សមាជិកគ្រប់គ្រងគម្រោង និងអ្នកសម្របសម្រួលនៃគណៈកម្មការចំពោះកិច្ច និងគណៈកម្មការប្រតិបត្តិ សម្រាប់អនុវត្តគម្រោងសាងសង់អគាររដ្ឋបាលថ្មីនៃរដ្ឋសភាកម្ពុជា ជាជំនួយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីឲ្យអង្គភាពគ្រប់គ្រងគម្រោងរាយការណ៍ជូន និងសុំយោបល់

ណែនាំពីថ្នាក់ដឹកនាំរដ្ឋសភា លើគម្រោងប្លង់មុននឹងអនុម័តជាមួយក្រុមហ៊ុន **អាកគីថេប ខេមបូឌា** Archetype Cambodia Ltd.។

-បានចាត់តំណាង ចំនួន២លើក នាំយកអំណោយផ្ទាល់ខ្លួន រួមមានគ្រឿងឧបភោគ បរិភោគ និងសម្ភារៈចាំបាច់មួយចំនួន ទៅប្រគល់ជូនគណៈអភិបាលស្រុកចំនួន៩ ក្នុងខេត្តកំពង់ធំ សម្រាប់ចែកជូន និងផ្គត់ផ្គង់ប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាតកំពុងធ្វើចត្តាឡីស័ក។

-បានចាត់តំណាងនាំយកថវិកាផ្ទាល់ខ្លួន ប្រគល់ជូនកាកបាទក្រហមកម្ពុជា ខេត្តកំពង់ធំ ដើម្បីចូលរួមអបអរសាទរខួប លើកទី១៥៨ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ឧសភា ឆ្នាំ២០២១ ក្រោមប្រធានបទ "ទាំងអស់គ្នារួមជាមួយកាកបាទក្រហមកម្ពុជាប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងកសាងភាពធន់របស់សង្គមជាតិ"។

## ៣.សកម្មភាព លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី អនុប្រធានទី២ នៃរដ្ឋសភា

នៅចន្លោះសម័យប្រជុំរដ្ឋសភាលើកទី៥ និងលើកទី៦ នីតិកាលទី៦ នេះ លោកជំទាវ បាន -ចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ចំនួន៥លើក -ប្រជុំរដ្ឋសភាជាវិសាមញ្ញ ចំនួន១លើក -ចុះមូលដ្ឋានក្នុងនាមសមាជិការដ្ឋសភាប្រចាំមណ្ឌលខេត្តកណ្ដាល និង -បានបំពេញការងារផ្សេងទៀត ដូចខាងក្រោម៖

-ដឹកនាំកិច្ចប្រជុំពិភាក្សាការងារ ដើម្បីត្រៀមចូលរួមកិច្ចពិភាក្សាទ្វេភាគីជាមួយសមភាគីសភាតំណាងប្រជាជនចិនទូទាំងប្រទេស ដែលនឹងប្រព្រឹត្តធ្វើតាមប្រព័ន្ធវីដេអូ។

-អម **ខ្ញុំប្រធានរដ្ឋសភា** ចូលរួមកិច្ចប្រជុំពិភាក្សាទ្វេភាគីជាមួយសមភាគីសភាតំណាងប្រជាជនចិនទូទាំងប្រទេស ដែលដឹកនាំដោយ **ឯកឧត្តម លី ចាងហ្ស៊ូ** ប្រធានសភាប្រជាជនចិនទូទាំងប្រទេស នៃសាធារណរដ្ឋប្រជាមានិតចិន។

-បន្ទាប់មកបានដឹកនាំគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភាកម្ពុជា ចូលរួមកិច្ចប្រជុំទ្វេភាគីជាមួយ **ឯកឧត្តម ចាន់ ឈុនស៊ាន** Zhang Chunxian អនុប្រធានសភាប្រជាជនចិនទូទាំងប្រទេស ដើម្បីពិភាក្សាអំពីប្រធានបទចំនួន៤ រួមមាន៖

១.ការផ្លាស់ប្ដូរបទពិសោធន៍ និងកិច្ចសហប្រតិបត្តិការផ្នែកច្បាប់

២.កិច្ចសហប្រតិបត្តិការអន្តរជាតិប្រឆាំងនឹងរោគរាតត្បាត

៣.ការស្ដារសេដ្ឋកិច្ចនាដំណាក់កាលក្រោយមេរោគរាលដាលជាសកល

៤.ស្ថានភាពអន្តរជាតិ និងក្នុងតំបន់ ដែលកិច្ចប្រជុំនេះបានប្រព្រឹត្តទៅតាមប្រព័ន្ធវីដេអូ នៅវិមានរដ្ឋសភា។

-ចូលរួមកិច្ចប្រជុំស្ដីពី "ការត្រៀមរៀបចំកិច្ចប្រជុំ អាស៊ិប ASEP លើកទី១១" ក្រោមការដឹកនាំកិច្ចប្រជុំដោយ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អនុប្រធានទី១នៃរដ្ឋសភា។**

-ធ្វើជាអធិបតីក្នុងពិធីជួបសំណេះសំណាលជាមួយរដ្ឋបាលឃុំ ស្រុក កងកម្លាំងការពារ ក្នុងស្រុកលើកដែក ខេត្តកណ្ដាល ស្ដីពីការចូលរួមក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩។

-ដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ ស្ដីពីសភាពការណ៍ទូទៅ -ការងារឆ្នាំ២០២០ និងទិសដៅភារកិច្ចឆ្នាំ២០២១ ព្រមទាំងពិធីសំណេះសំណាលសួរសុខទុក្ខជាមួយបងប្អូនក្រុមការងារនៅថ្នាក់មូលដ្ឋាន ក្នុងស្រុកលើកដែក ខេត្តកណ្ដាល។

-ចូលរួមកិច្ចប្រជុំការិយាល័យនយោបាយរបស់ **អាយកាប់** ICAPP ដែលជាកិច្ចប្រជុំចង្អៀត តាមប្រព័ន្ធវីដេអូ ផ្សាយចេញពីសាធារណរដ្ឋកូរ៉េ។

-ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១ របស់ **អាយកាប់-កម្ពុជា** (ICAPP-កម្ពុជា) និង **អេស៊ីស៊ី-កម្ពុជា** (ACC-កម្ពុជា)។

-ដឹកនាំកិច្ចប្រជុំលើកទី១ ក្រុមការងារខ្លឹមសារព័ត៌មាន ផ្សព្វផ្សាយ រដ្ឋបាល ហិរញ្ញវត្ថុ និងពិធីការ ដើម្បីត្រៀមរៀបចំទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ឧសភា ឆ្នាំ២០២១ និងព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** និងជាព្រះប្រធានកិត្តិយសកាកបាទក្រហមកម្ពុជា នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា។

-ដឹកនាំកិច្ចប្រជុំពិភាក្សាស្តីពី **"សារប្រយោជន៍នៃការមកពិនិត្យផ្ទៃពោះ និងការថែទាំក្រោយសម្រាលក្នុងអំឡុងពេលមានការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩"** នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា ក្រោមគំនិតផ្តួចផ្តើមរបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា។

-ដឹកនាំកិច្ចប្រជុំត្រៀមរៀបចំកិច្ចប្រជុំលើកទី២ នៃក្រុមប្រឹក្សាវប្បធម៌អាស៊ី **អេស៊ីស៊ី** ACC ដែលកម្ពុជានឹងត្រូវធ្វើជាម្ចាស់ផ្ទះ។

-ដឹកនាំកិច្ចប្រជុំលើកទី២ ក្រុមប្រឹក្សាវប្បធម៌អាស៊ី ដែលជាសន្និសីទតាមប្រព័ន្ធវីដេអូ ក្រោមប្រធានបទ **"ការពង្រឹងវប្បធម៌ និងនវានុវត្តន៍ ដើម្បីវិបុលភាពរួមក្នុងអំឡុងពេលនិងក្រោយកូវីដ-១៩"** ក្នុងនាមកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

-បានអនុញ្ញាតិឲ្យ **លោក ចំរើន សុផល** អគ្គលេខាធិការអង្គការសហព័ន្ធសន្តិភាពសកលកម្ពុជា ជាតំណាងដ៏ខ្ពង់ខ្ពស់ **លោកស្រីបណ្ឌិត ហាក់ ចាហាមូន** សហស្ថាបនិកសហព័ន្ធសន្តិភាពសកល **យូភីអេហ្វ** UPF ចូលជួបសំណេះសំណាល នៅវិមានរដ្ឋសភា។

-បានទទួលជំនួយឧបត្ថម្ភពីអគ្គនាយកក្រុមហ៊ុនផលិតទឹកបរិសុទ្ធអេរ៉ូទិច ដើម្បីចូលរួមសកម្មភាពមនុស្សធម៌ ក្នុងយុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ នៅមូលដ្ឋានស្រុកលើកដែក ខេត្តកណ្តាល រួមមានគ្រឿងឧបភោគបរិភោគ ជាអង្ករ មី ទឹកបរិសុទ្ធ ត្រីខកំប៉ុង នំសុខភាព អាល់កុល ព្រមទាំងបរិក្ខារពេទ្យ មួយចំនួនផងដែរ សរុបចំនួន០១រថយន្តធុនធំ។

-បានចាត់តំណាងនាំយកអំណោយប្រគល់ជូនឃុំចំនួន០៤ នៃស្រុកលើកដែក ខេត្តកណ្តាល ដើម្បីបន្តយកទៅចែកជូនប្រជាពលរដ្ឋក្រីក្រកំពុងជួបការលំបាកខ្វះខាត ក្នុងពេលប្រឈមជាមួយមេរោគរាតត្បាតកូវីដ-១៩ សរុបចំនួន ១៨៦០គ្រួសារ និងសម្រាប់ប្រើប្រាស់ក្នុងការរួមចំណែកជាមួយរាជរដ្ឋាភិបាល ដើម្បីប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ជាពិសេសក្នុងព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ ក្នុងនោះមានឃុំព្រែកដាច់ ឃុំខ្ពបអាទាវ ឃុំពាមរាំង និងឃុំសណ្តារ រួមមានគ្រឿងឧបភោគបរិភោគ ដូចជា អង្ករ ទឹកបរិសុទ្ធ មី ត្រីខកំប៉ុង និងសម្ភារៈបរិក្ខារពេទ្យ ព្រមទាំងថ្នាំពេទ្យ សរុបចំនួន០៣រថយន្តធុនធំ។

-បានផលិតវីដេអូថ្លែងសុន្ទរកថា សម្រាប់ត្រៀមចូលរួមកិច្ចសន្ទនាពិសេស តាមរយៈប្រព័ន្ធវីដេអូក្រោមចំណងជើងថា **"សមិទ្ធផលរបស់ក្រុងសៀងហៃក្នុងការអនុវត្តគំនិត ស៊ី ជីនភីង ស្តីពីសង្គមនិយមមានលក្ខណៈពិសេសចិនសម្រាប់យុគ្គសម័យថ្មី"** ដោយផ្តោតលើប្រធានបទ **"ធ្វើអោយសុបិនក្លាយជាការពិត ចែករំលែកភាពអស្ចារ្យ"** ផ្សាយចេញពីទីក្រុងសៀងហៃប្រទេសចិន ។

-បានឧបត្ថម្ភដល់កងកម្លាំងដែលរួមសហការក្នុងកិច្ចប្រតិបត្តិការ ជួយទប់ស្កាត់ការរីករាលដាលនៃមេរោគកូវីដ-១៩ នៅតំបន់បិទខ្ទប់តាមបណ្តាភូមិមួយចំនួននៃស្រុកលើកដែក នូវគ្រឿងឧបភោគបរិភោគ គ្រឿងបរិក្ខារពេទ្យសម្រាប់ការពារ និងថវិកាមួយចំនួនផងដែរ។

-បានចាត់តំណាងនាំយកគ្រឿងឧបភោគបរិភោគ គ្រឿងបរិក្ខារពេទ្យ និងថវិកាមួយចំនួន ទៅឧបត្ថម្ភជូនប្រជាពលរដ្ឋដែលស្ថិតក្នុងតំបន់បិទខ្ទប់ ចំនួន០៣ភូមិ ក្នុងឃុំពាមរាំង នៃស្រុកលើកដែក ក្នុងនោះមានភូមិថ្មី ភូមិព្រែកតាទួន និងភូមិពាមរាំងលើ។

-បានចូលរួមជួយឧបត្ថម្ភជាថវិកាដល់ប្រជាពលរដ្ឋដែលរងគ្រោះថ្នាក់ដោយការបាក់ច្រាំងទន្លេ ធ្វើឲ្យប៉ះពាល់ដល់ទីលំនៅ និងផលដំណាំរបស់ប្រជាពលរដ្ឋចំនួន១៨គ្រួសារ នៅភូមិព្រែកដាច់ ឃុំព្រែកដាច់ ស្រុកលើកដែក។

-បានចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆមាស របស់ក្រុមការងារខេត្តកណ្តាល និងលើកទិសដៅអនុវត្តបន្ត ដែលបានប្រព្រឹត្តធ្វើនៅក្រុងតាខ្មៅ ខេត្តកណ្តាល។

-បានចូលរួមជាថវិកាជូនកាកបាទក្រហមកម្ពុជា សម្រាប់ថ្ងៃ៨ឧសភា មានដូចខាងក្រោម៖

១. សម្រាប់សាងសង់ផ្ទះជូនយុទ្ធជនក្រីក្រ និងអតីតយុទ្ធជនមានពិការភាព នៅដំណាក់ត្រយឹង ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តកំពង់ស្ពឺ

២. សម្រាប់អបអរសាទរខួប លើកទី១៥៨ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ឧសភា ឆ្នាំ២០២១ ក្រោមប្រធានបទ **"ទាំងអស់គ្នារួមជាមួយកាកបាទក្រហមកម្ពុជាប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងកសាងភាពធន់របស់សង្គមជាតិ"** ជូនដល់បណ្តាសាខាកាកបាទក្រហមកម្ពុជា រួមមាន៖ -នៅថ្នាក់កណ្តាល រាជធានីភ្នំពេញ -សាខាខេត្តកណ្តាល -សាខាខេត្តប៉ៃលិន និង-អនុគណៈកម្មការសាខាកាកបាទក្រហមស្រុកលើកដែក។

-ជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ប្រធានកាកបាទក្រហមកម្ពុជា បានចុះសំណេះសំណាល និងចែកអំណោយមនុស្សធម៌ជូនដល់បងប្អូននៅតំបន់បិទខ្ទប់ ចំនួន២លើក៖

១.នៅភូមិពាមរាំងលើ ឃុំពាមរាំង ស្រុកលើកដែក សរុបចំនួន៣៣៣គ្រួសារ

២.នៅសាលាគរុកោសល្យខេត្តកណ្តាល។

-ដឹកនាំកិច្ចប្រជុំបូកសរុបការងារស្រុកលើកដែក ប្រចាំឆមាសទី១ និងវិធានការឲ្យអនុវត្តបន្ត។

-បានចូលរួមកិច្ចប្រជុំតាមប្រព័ន្ធវីដេអូ ផ្សាយចេញពីសហព័ន្ធរុស្ស៊ី ជាមួយតំណាងនៃបណ្តាប្រទេសអាស៊ាន ក្រោមប្រធានបទ **"តួនាទីរបស់កម្លាំងនយោបាយដែលមានការទទួលខុសត្រូវ ក្នុងការកសាងទំនាក់ទំនងវប្បធម៌គ្នាទៅវិញទៅមកប្រកបដោយប្រសិទ្ធភាព"** ក្នុងក្របខណ្ឌនៃព្រឹត្តិការណ៍ម៉ារ៉ាតុនវប្បធម៌ **"ពីអាត្លង់ទិករហូតដល់មហាសមុទ្រប៉ាស៊ីហ្វិក"**។

-ជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ប្រធានកាកបាទក្រហមកម្ពុជា នាំយកទេយ្យវត្ថុ និងបច្ច័យ ទៅប្រគេន សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រមទាំងព្រះសង្ឃគង់នៅវត្តឧណ្ណាលោម និងវត្តបុទុមវត្តីរាជវរារាម ក្នុងឱកាសព្រះរាជពិធីចម្រើនព្រះជន្មវស្សា **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ**។

-បានអនុញ្ញាតិឲ្យ **លោក គឹម យាត ដារ៉ារិទ្ធ** នាយកប្រតិបត្តិមជ្ឈមណ្ឌលសភាអាស៊ី ចូលជួបពិភាក្សាការងារ។

-បានចូលរួមកិច្ចសន្ទនាពិសេសក្រោមចំណងជើងថា **"សមិទ្ធផលរបស់ក្រុងសៀងហៃ ក្នុងការអនុវត្ត គំនិត ស៊ី ជីនភីង ស្តីពីសង្គមនិយមមានលក្ខណៈពិសេសចិន សម្រាប់យុគ្គសម័យថ្មី"** ដោយផ្តោតលើប្រធានបទ **"ធ្វើអោយសុបិនក្លាយជាការពិត ចែករំលែកភាពអស្ចារ្យ"** ដែលបានប្រព្រឹត្តធ្វើតាមរយៈប្រព័ន្ធវីដេអូ ផ្សាយចេញពីទីក្រុងសៀងហៃ ប្រទេសចិន។

## VI. សកម្មភាពរបស់គណៈកម្មការនីមួយៗនៃរដ្ឋសភា

### ១.គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា

គណៈកម្មការទី១នៃរដ្ឋសភា បាន៖

+ប្រជុំផ្ទៃក្នុងគណៈកម្មការ ចំនួន០១លើក។

+ដឹកនាំកិច្ចប្រជុំពិភាក្សាការងារត្រៀម និងដឹកនាំគណៈប្រតិភូសភាជាតិកម្ពុជា ចូលរួមកិច្ចប្រជុំគណៈកម្មការសហប្រតិបត្តិការ និងអភិវឌ្ឍន៍ នៃមហាសន្និបាតលើកទី៤៦ អេប៉េអេហ្វ APF តាមប្រព័ន្ធវីដេអូភ្ជាប់វិមានរដ្ឋសភា ទៅទីក្រុងប៉ារីស ប្រទេសបារាំង។

+ជួបពិភាក្សាការងារ ចំនួន៣លើក រួមមាន៖ ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ ឯកឧត្តមអភិបាលរង នៃគណៈអភិបាលខេត្តកោះកុង និង ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តពោធិ៍សាត់ និងអាជ្ញាធរគ្រប់លំដាក់ថ្នាក់ ព្រមទាំងមន្ទីរពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈកម្មការ ក្នុងគោលបំណងសិក្សាស្វែងយល់អំពីការរីកចម្រើន និងយន្តការដោះស្រាយទំនាស់ដីធ្លីរបស់ខេត្ត ក្នុងឱកាសនោះគណៈកម្មការក៏បានចុះទស្សកិច្ចនៅវារីអគ្គិសនីតាតៃ វារីអគ្គិសនីអាតៃ និងចុះទស្សនកិច្ចនៅព្រំដែនថ្មដាផងដែរ។

+បានចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ មេឃុំ ស្មៀនឃុំ នាយប៉ុស្តិ៍ នាយកសាលា ប្រធានមណ្ឌលសុខភាព ប្រធានភូមិ ដោយមានអ្នកចូលរួមប្រមាណ២០០នាក់ នៅក្នុងឃុំចំនួន៥ រួមមាន៖ ឃុំជប់ ឃុំស្រឡប់ ឃុំបឹងព្រួល ក្នុងស្រុកត្បូងឃ្មុំ និងឃុំព្រែកអាជី ឃុំកំពង់ទ្រាស ក្នុងស្រុកក្រូចឆ្មារ ដើម្បីសាកសួរសុខទុក្ខអំពីជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងស្តាប់សំណូមពរ បញ្ហាប្រឈម និងដោះស្រាយកង្វល់របស់អាជ្ញាធរមូលដ្ឋានក្នុងអំឡុងពេលជំងឺកូវីដ-១៩ កំពុងរាតត្បាតជាសកល ដោយបានឧបត្ថម្ភជាសម្ភារៈ និងថវិកាមួយចំនួន។

+ដឹកនាំសមត្ថកិច្ចរដ្ឋបាលពាក់ព័ន្ធនៃខេត្តត្បូងឃ្មុំ ចុះពិនិត្យសិក្សាលើគម្រោងចំណាយសម្រាប់ជួសជុល និងកសាងប្រព័ន្ធធារាសាស្ត្រ ចំនួន៦គម្រោង នៅ៦ឃុំ ក្នុងស្រុកត្បូងឃ្មុំ រួមមាន៖ ឃុំពាមជីលាំង ឃុំជីរោទ៍ទី១ ឃុំជីរោទ៍ទី២ ឃុំថ្មពេជ្រ ឃុំគរ និងឃុំអញ្ចើម។

+ចុះត្រួតពិនិត្យការសាងសង់ប្រឡាយទឹក២,៥០០ម៉ែត្រ និងទ្វារទឹកចំនួន៤កន្លែង ជូនដល់ប្រជាពលរដ្ឋចំនួន ៤ឃុំ សម្រាប់ប្រើប្រាស់ស្រោចស្រពដីស្រែ និងដំណាំ គឺស្ថិតនៅឃុំជីរោជ៍១ ឃុំពាមជីលាំង ឃុំថ្មពេជ្រ ឃុំគរ និងឃុំថ្មពេជ្រ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដោយមានការចូលរួមពីសំណាក់ អភិបាលរងខេត្ត ក្រុមប្រឹក្សាស្រុក អភិបាលស្រុក ប្រធាន អនុប្រធានមន្ទីរពាក់ព័ន្ធជុំវិញខេត្ត លោកមេឃុំ មេភូមិ ព្រមទាំងប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

+គណៈកម្មការបានទទួលពាក្យបណ្ដឹងសរុប ចំនួន២០រឿង មកពីរាជធានី-ខេត្ត ក្នុងនោះ៖ -បានធ្វើលិខិតអន្តរាគមន៍ ចំនួន១២រឿង កំពុងពិនិត្យ ចំនួន០៦រឿង តម្កល់មិនចាត់ការ ចំនួន០២រឿង។ ចំពោះពាក្យបណ្ដឹងបញ្ជូនត្រឡប់ទៅវិញ ចំនួន០២រឿង និងទទួលបានលិខិតឆ្លើយតប ចំនួន០៦រឿង។

## ២.គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

គណៈកម្មការទី២នៃរដ្ឋសភា បាន៖

+ដឹកនាំប្រជុំផ្ទៃក្នុងគណៈកម្មការ ចំនួន៥លើក៖ -ដើម្បីពិនិត្យពិភាក្សាការងាររបស់គណៈកម្មការដែលបានអនុវត្តកន្លងមក និងផែនការចុះបំពេញបេសកកម្មក្នុងចន្លោះសម័យប្រជុំរដ្ឋសភា (វិស្សមកាលរដ្ឋសភា) -ពិភាក្សាការងារដកស្រង់បទពិសោធន៍នៅតាមបណ្ដាខេត្តនានា បន្ទាប់ពីការចុះបំពេញបេសកកម្មរបស់គណៈកម្មការ និងបញ្ហាផ្សេងៗ -ពិនិត្យលើក្របខ័ណ្ឌគោលនយោបាយ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ និង -ពិនិត្យសិក្សាសេចក្ដីព្រាងច្បាប់ ចំនួន២។

+ចូលរួមកិច្ចប្រជុំពិភាក្សាគណៈកម្មការសាងសង់អគាររដ្ឋបាលថ្មីកំពស់១២ជាន់ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ក្រោមជំនួយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោមអធិបតីភាព **ឯកឧត្ដមកិត្តិនីតិកោសលបណ្ឌិត** អនុប្រធានទី១នៃរដ្ឋសភា។

+ចូលរួមប្រជុំដើម្បីត្រៀមចូលរួមកិច្ចពិភាក្សាទ្វេភាគីតាមរយៈប្រព័ន្ធវីដេអូ រវាងសមភាគីរដ្ឋសភាកម្ពុជា និងសភាតំណាងប្រជាជនចិនទូទាំងប្រទេស ក្រោមអធិបតី **លោកជំទាវកិត្តិសង្គហបណ្ឌិត** អនុប្រធានទី២ នៃរដ្ឋសភា។

+ចុះបំពេញបេសកកម្មតាមបណ្ដាខេត្ត ចំនួន៣លើក រួមមាន៖ ខេត្តស្ទឹងត្រែង ខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ ដើម្បីសិក្សាស្វែងយល់អំពីវឌ្ឍនភាពការងារ ប្រសិទ្ធភាពនៃការអនុវត្តច្បាប់នានា បញ្ហាប្រឈមរបស់ខេត្ត និងផលប៉ះពាល់សេដ្ឋកិច្ច ដែលបណ្ដាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងនោះក៏មានការចូលរួមពី ឯកឧត្ដមជាតំណាងរាស្ត្រមណ្ឌលខេត្តស្ទឹងត្រែង និងតំណាងមកពីអាជ្ញាធរសវនកម្មជាតិ ផងដែរ។

+ដឹកនាំប្រជុំអនុគណៈកម្មការហិរញ្ញវត្ថុ ផ្គត់ផ្គង់ និងភស្តុភារ នៃកិច្ចប្រជុំ **អាសិប លើកទី១១** ASEP-11 ដើម្បីពិភាក្សាលើគម្រោងថវិកាជាតិ សម្រាប់ការចំណាយរៀបចំកិច្ចប្រជុំ **អាសិប លើកទី១១** ដែលសភាកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ។

+បានប្រជុំផ្ទៃក្នុងគណៈកម្មការ ប្រជុំជាមួយបណ្ដាគណៈកម្មការនានានៃរដ្ឋសភា និងប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសេចក្ដីព្រាងច្បាប់ចំនួន៤ ដែលគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាប្រគល់ជូនគណៈកម្មការពិនិត្យសិក្សា។

+បានដឹកនាំប្រជុំត្រៀមចូលរួមមហាសន្និបាតអាយប៉ា លើកទី៤២ និងការងារត្រៀមរៀបចំមហាសន្និបាតអាយប៉ា លើកទី៤៣ ជាមួយ សមាជិក សមាជិកាក្រុមអាយប៉ាជាតិ-កម្ពុជា ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានរដ្ឋសភា និងមន្ត្រីជំនាញពាក់ព័ន្ធ ចំនួន២លើក។

+ដឹកនាំប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល តាមប្រព័ន្ធវីដេអូ ដើម្បីពិនិត្យ ពិភាក្សាលើ សេចក្ដីព្រាងច្បាប់ ចំនួន២។

## ៣.គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក

គណៈកម្មការទី៣នៃរដ្ឋសភា បាន៖

+ប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិភាក្សាខ្លឹមសារសម្រាប់សមាជិករដ្ឋសភា ប្រចាំមណ្ឌលខេត្តនីមួយៗ ដើម្បីស្វែងយល់ និងក្តាប់ភារកិច្ចលើវិស័យពាក់ព័ន្ធនឹងគណៈកម្មការ ជាពិសេសវិស័យកសិកម្ម និងបរិស្ថាន និងរៀបចំកម្មវិធីចុះបំពេញបេសកកម្មតាមបណ្តាខេត្តក្នុងពេលវិស្សមកាលនៃរដ្ឋសភា។

+ចូលរួមពិភាក្សាលើករណីប្រជាជនកាន់កាប់ និងអាស្រ័យផលនៅក្នុងដែនជម្រកសត្វព្រៃ ភ្នំត្នោត ភ្នំពក នៅទីចាត់ការដែនជម្រកសត្វព្រៃបឹងពែង ក្នុងខេត្តព្រះវិហារ។

+ចូលរួមស្តាប់ និងអង្កេត ក្នុងកិច្ចប្រជុំអន្តរក្រសួង ចំនួន៣លើក ស្តីពី"**វឌ្ឍនភាពនៃការងារពិនិត្យ សិក្សា និងចងក្រងឯកសារទីតាំងដីដែលប្រជាពលរដ្ឋបានប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែង ក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ នៅក្នុងភូមិសាស្ត្រ រួមមាន៖ ខេត្តកែប ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តឧត្តរមានជ័យ និង ខេត្តព្រះវិហារ**" នៅទីស្តីការក្រសួងបរិស្ថាន ។

+ចូលរួមពិធីផ្សព្វផ្សាយរបាយការណ៍បច្ចុប្បន្នភាព ការរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុញ្ញាក្រប ខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ នៅទីស្តីការក្រសួងបរិស្ថាន។

+ចុះទស្សនកិច្ចសិក្សាស្វែងយល់អំពីបច្ចេកទេស និងសង្វាក់ផលិតកម្មដំណាំចេកអំបូងលឿង ខ្នារការុត ធុរនេ ក្រូចថ្លុង កន្លែងផលិតជីសរីរាង្គ របស់ **ក្រុមហ៊ុន ឡុង ស្រេង អ៊ិនធើណេសិនណល** ស្ថិតនៅស្ថិតក្នុងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

+ធ្វើជាអធិបតីក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវផ្លូវបេតុងអាម៉េ ប្រវែង៦៥៧ម៉ែត្រ ក្នុងឃុំកំភុន ស្រុកសេសាន ខេត្តស្ទឹងត្រែង។

## ៤.គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ

គណៈកម្មការទី៤នៃរដ្ឋសភា បាន៖

+ចូលរួមជាគណៈអធិបតីក្នុងពិធីបិទកិច្ចប្រជុំក្រុមប្រឹក្សាជាតិ និងគណៈកម្មាធិការប្រតិបត្តិជាតិ របស់សមាគមជាតិក្រុមប្រឹក្សារាជធានី-ខេត្ត។

+ដឹកនាំកិច្ចប្រជុំអនុគណៈកម្មការទី៥៖ សន្តិសុខ សណ្តាប់ធ្នាប់ និងសង្គ្រោះបឋម នៃកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប លើកទី១១ ដើម្បីរៀបចំផែនការការពារសន្តិសុខ រក្សាសុវត្ថិភាព និងសណ្តាប់ធ្នាប់ ជូនគណៈប្រតិភូ និងកិច្ចប្រជុំទាំងមូល ដែលសភាកម្ពុជានឹងត្រូវធ្វើជាម្ចាស់ផ្ទះនៅពេលខាងមុខ។

+ចូលរួមប្រជុំស្តីពីការត្រៀមរៀបចំកិច្ចប្រជុំអាសិប លើកទី១១ ក្រោមការដឹកនាំ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អនុប្រធានទី១នៃរដ្ឋសភា** និងជាប្រធានគណៈកម្មការរៀបចំកិច្ចប្រជុំអាសិប លើកទី១១។

+បានចូលរួមកិច្ចប្រជុំរៀបចំខ្លឹមសារសម្រាប់ក្រុមពិភាក្សាទី១ (Panel Disscussion1) នៃកិច្ចប្រជុំអាសិប លើកទី១១ ចំនួន២លើក។

+ចូលរួមអមដំណើរ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំនួន២លើក រួមមាន ៖ -ការចុះទស្សនកិច្ចស្វែងយល់អំពីបច្ចេកទេស និងសង្វាក់ផលិតកម្មដំណាំចេកអំបូងលឿង កន្លែងផលិតជីសរីរាង្គ រោងចក្រផលិតក្រដាសឡាំងសម្រាប់វេចខ្ចប់ចេក និងសំណេះសំណាលជាមួយបុគ្គលិករបស់ក្រុមហ៊ុន **ឡុង ស្រេង អ៊ិនធើណេសិនណល** (Long Sreng International Co., LTD) ស្ថិតនៅក្នុងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម និង -ការចុះទស្សនកិច្ចនៅការដ្ឋានបោសសម្អាតគ្រាប់មីនមិនទាន់ផ្ទុះ ក្នុងនាវាចម្បាំងលិចក្នុងទន្លេ ស្ថិតនៅក្នុងភូមិវាល ឃុំមានជ័យ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

+ចូលរួមពិធីសម្ពោធជាផ្លូវការមន្ទីរពេទ្យនគរបាលខេត្តបាត់ដំបង ដែលជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចក្រឡាហោម** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅខេត្តបាត់ដំបង។

+ចូលរួមអមដំណើរ **សម្តេចក្រឡាហោម** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោកជំទាវ ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារសិក្សា និងសមិទ្ធផលផ្សេងៗនៅក្នុង សាលាបឋមសិក្សា **សម្តេច ជា ស៊ីម** ក្នុងភូមិបែកចាន សង្កាត់ព្រែកព្រះស្តេច ក្រុងបាត់ដំបង និងបានបន្តដំណើរប្រគល់សញ្ញាបត្រដល់និស្សិតសាកលវិទ្យាល័យជាតិបាត់ដំបង ចំនួន២,០២៣នាក់ (ស្រី១,០៥០នាក់) នៅសាកលវិទ្យាល័យបាត់ដំបង ។

+ចូលរួមប្រជុំតាមប្រព័ន្ធវីដេអូ ដើម្បីត្រៀមចូលរួមមហាសន្និបាតសហភាពអន្តរសភា អាយភីយូ IPU លើកទី១៤២។

+ចូលរួមប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាពិគ្រោះយោបល់អាយប៉ា ស្តីពីគ្រឿងញៀន លើកទី៤ តាមរយៈប្រព័ន្ធវីដេអូ។

+អម **ខ្ញុំប្រធានរដ្ឋសភា** ក្នុងជំនួបទ្វេភាគីជាមួយ **ប្រធានរដ្ឋសភាវៀតណាម** តាមរយៈប្រព័ន្ធវីដេអូ។

+ចូលរួមប្រជុំត្រៀមការចូលរួមកិច្ចប្រជុំ អាយប៉ា AIPA លើកទី៤២។

+ដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមពិធីបើកកិច្ចប្រជុំរបស់ការិយាល័យអង្គការសហប្រជាជាតិប្រឆាំងអំពើភេរវកម្ម តាមរយៈប្រព័ន្ធវីដេអូ ផ្សាយចេញពីទីក្រុងដូហា ប្រទេសកាតា។

+ចូលរួមក្នុងពិធីសម្ពោធសមិទ្ធផលនានាក្នុងរយៈពេល១ឆ្នាំ នៅតំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្ម X16 ក្នុងឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ក្រោមអធិបតីភាព **សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិកម្ពុជា និង **ឧត្តមសេនីយ៍ឯកបម្រុង ហ្វាន វ៉ាន់ហ្សាង** រដ្ឋមន្ត្រីក្រសួងការពារជាតិវៀតណាម។

+ចូលរួមប្រជុំជាមួយគណៈកម្មទី២ និងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ សិក្សាសេចក្តីព្រាងច្បាប់ចំនួន២។

## ៥.គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

គណៈកម្មការទី៥នៃរដ្ឋសភា បាន៖

+ចូលរួមប្រជុំ និងរៀបចំខ្លឹមសារសម្រាប់ក្រុមពិភាក្សាទី១ និង ក្រុមពិភាក្សាទី៣ នៃកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប ASEP លើកទី១១ ចំនួន៤លើក ដើម្បីពិភាក្សាលើខ្លឹមសារ និងឯកសារបំពេញបន្ថែម។

+ដឹកនាំគណៈប្រតិភូសភាជាតិកម្ពុជា ចូលរួមកិច្ចប្រជុំសភានិយាយភាសាបារាំង **អាប៉េអេហ្វ** APF ស្តីពីគណៈកម្មការកិច្ចការសភា តាមប្រព័ន្ធវីដេអូ ដែលផ្សាយចេញពីទីក្រុងប៉ារីស ប្រទេសបារាំង។

+ដឹកនាំកិច្ចសវនាការសភា នៅអង្គការសហប្រជាជាតិ និងអន្តរសភា ស្តីពីការប្រយុទ្ធប្រឆាំងអំពើពុករលួយ តាមប្រព័ន្ធវីដេអូ ដែលភ្ជាប់ពីវិមានរដ្ឋសភា ទៅកាន់ទីស្នាក់ការអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉កសហរដ្ឋអាមេរិក។

+ដឹកនាំកិច្ចប្រជុំត្រួតពិនិត្យការងារចំណាកស្រុក នៅស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ដែលមានប្រជាពលរដ្ឋចំណាកស្រុកសរុប ១,៤០០នាក់ ក្នុងចំណាកស្រុកទៅប្រទេសថៃ ចំនួន១,០៦៦នាក់។

+ចូលរួមពិធីបើកកិច្ចប្រជុំក្រុមប្រឹក្សាវប្បធម៌អាស៊ីលើកទី២ ក្រោមប្រធានបទស្តីពី "**ការលើកកម្ពស់វប្បធម៌ និងនវានុវត្តន៍ដើម្បីវិបុលភាពរួមក្នុងអំឡុងពេល និងក្រោយកូវីដ-១៩**" តាមប្រព័ន្ធវីដេអូ នៅវិមានរដ្ឋសភាដែលផ្សាយចេញពី សាធារណរដ្ឋកូរ៉េ។

+បានទទួលនូវ **គ្រឿងឥស្សរិយយស សម្រាប់និទាឃរដូវឆ្នាំ២០២១** ពីរាជរដ្ឋាភិបាលជប៉ុន ដែលគ្រឿងឥស្សរិយយសនេះ រាជរដ្ឋាភិបាលជប៉ុនផ្តល់ជូនឥស្សរជនបរទេស ចំពោះបុគ្គលមានគុណសម្បត្តិ ដើម្បីជាការទទួលស្គាល់នូវកិច្ចការបម្រើជាតិ ឬបម្រើសង្គមរបស់ឥស្សរជននោះ និងជាការសម្តែងនូវការគោរព និងកោតសរសើរ ចំពោះស្នាដៃលេចធ្លោរបស់បុគ្គលឆ្នើមទាំងនោះ ក្នុងវិស័យផ្សេងៗនៅក្នុងសង្គម។

+ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពីកិច្ចការសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាពនៃសភាតំបន់អាស៊ី អេភីអេ APA ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងសេចក្តីសម្រេចមួយចំនួន រៀបចំដោយរដ្ឋសភាប្រទេសបារ៉ែន តាមប្រព័ន្ធវីដេអូ។

+ជួបពិភាក្សាការងារជាមួយ **ឯកឧត្តម ក្លូស វែល** Klaus Welle អគ្គលេខាធិការសភាអឺរ៉ុប តាមប្រព័ន្ធអ៊ីនធើណែត ស្តីពី "កិច្ចសហប្រតិបត្តិការសភា ក្នុងភាពជាដៃគូសហភាពអឺរ៉ុប-អាស៊ាន"។

+អម **ខ្ញុំប្រធានរដ្ឋសភា** ចំនួន៣លើក ក្នុងនោះជួបសម្តែងការគួរសមជាមួយ ឯកអគ្គរដ្ឋទូតនានាប្រចាំកម្ពុជា ចំនួន២លើក និង ជំនួបទ្វេភាគីជាមួយ **ប្រធានរដ្ឋសភាវៀតណាម** ១លើក។

+ដឹកនាំប្រជុំដើម្បីពិនិត្យខ្លឹមសារឯកសារ សម្រាប់ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមអ្នកនយោបាយអាយប៉ាលើកទី១២ (12-AIPA Caucus)។

+ចូលរួមប្រជុំត្រៀមការចូលរួមកិច្ចប្រជុំ អាយប៉ា AIPA លើកទី៤២។

+ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមអ្នកនយោបាយអាយប៉ា លើកទី១២ (12-AIPA Caucus) តាមប្រព័ន្ធវីដេអូ ផ្សាយចេញពីប្រទេសសិង្ហបុរី។

+ដឹកនាំកិច្ចប្រជុំត្រៀមរៀបចំសន្និសីទលើកទី៨ នៃគណៈកម្មការកិច្ចបរទេសនៃរដ្ឋសភា កម្ពុជា-ឡាវ និងវៀតណាម (CLV) តាមប្រព័ន្ធវីដេអូ។

+ចូលរួមប្រជុំជាមួយគណៈកម្មការទី២ និងតំណាងរាជរដ្ឋាភិបាល តាមប្រព័ន្ធវីដេអូ ដើម្បីពិនិត្យសិក្សា សេចក្តីព្រាងច្បាប់ចំនួន២។

+ចូលរួមកិច្ចប្រជុំដើម្បីពិនិត្យពិភាក្សាលើ "ការស្នើសុំកាត់បន្ថយ កិច្ចប្រជុំក្រុមពិភាក្សាចំនួន១ ក្នុងចំណោមកិច្ចប្រជុំក្រុមពិភាក្សា ចំនួន៣ នៃកិច្ចប្រជុំASEP-11" តាមប្រព័ន្ធវីដេអូ។

## ៦.គណៈកម្មការនីតិកម្ម និងយុត្តិធម៌

គណៈកម្មការទី៦នៃរដ្ឋសភាបាន៖

+ប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

+ចូលរួមអមគណៈអធិបតី ក្នុងកម្មវិធីដំណើរទស្សនកិច្ចស្វែងយល់របស់ប្រតិភូសិក្ខាកាម នៃវគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ជំនាន់ទី២៤ នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស នៅវិមានព្រឹទ្ធសភា។

+ដឹកនាំកិច្ចប្រជុំដើម្បីពិនិត្យពិភាក្សាលើ **"សេចក្តីព្រាងមូលបទ និងប្រធានបទ នៃកិច្ចប្រជុំ អាស៊ីបលើកទី១១"** ក្នុងនាមជាប្រធានអនុគណៈកម្មការទី១ (ខ្លឹមសារ និងឯកសារ) នៃគណៈកម្មការរៀបចំកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប លើកទី១១។

+ដឹកនាំគណៈប្រតិភូក្រុមសភាជាតិកម្ពុជា ចូលរួមមហាសន្និបាតលើកទី៤៦ នៃសភានិយាយភាសាបារាំង **អាប៉េអេហ្វ** APF តាមប្រព័ន្ធវីដេអូ ដែលផ្សាយចេញពីទីក្រុងប៉ារីស ប្រទេសបារាំង។

+ចូលរួមកិច្ចប្រជុំគណៈកម្មាធិការនាយកបណ្តាញស្ត្រី នៃសភានិយាយភាសាបារាំង អាប៉េអេហ្វ APF តាមប្រព័ន្ធវីដេអូ ចំនួន២លើក ដឹកនាំដោយ **លោកជំទាវ ទី ប៉ូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ និង **ឯកឧត្តម សុខ ឥសាន** ប្រធានគណៈកម្មការទី៤ នៃព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។

+ដឹកនាំប្រជុំសហការជាមួយគណៈកម្មការទី៨នៃរដ្ឋសភា ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី វិធានការទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដោយមានតំណាងគណៈកម្មការទាំង១០នៃរដ្ឋសភា ចូលរួម។

+បានដឹកនាំកិច្ចប្រជុំដើម្បីពិនិត្យពិភាក្សាលើ "ការស្នើសុំកាត់បន្ថយ កិច្ចប្រជុំក្រុមពិភាក្សាចំនួន១ ក្នុងចំណោមកិច្ចប្រជុំក្រុមពិភាក្សា ចំនួន៣ នៃកិច្ចប្រជុំASEP-11" តាមប្រព័ន្ធវីដេអូ។

## ៧.គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍

គណៈកម្មការទី៧នៃរដ្ឋសភា បាន៖

-ប្រជុំផ្ទៃក្នុងគណៈកម្មការ ចំនួន១លើក ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងរបាយការណ៍សកម្មភាពការងាររបស់គណៈកម្មការ និងទិសដៅបន្តឆ្នាំ២០២១ ព្រមទាំងពិនិត្យ និងកែសម្រួលលើសេចក្តីសម្រេចស្តីពីការបែងចែកក្រុមការងារទទួលបន្ទុកតាមវិស័យ និងភារកិច្ចរបស់សមាសភាពគណៈកម្មការទី៧។

-ចុះទស្សនកិច្ចនៅ **វិទ្យាល័យព្រះស៊ីសុវត្ថិ** និង **សាលាប៊ែលធី អន្តរជាតិ ទី១៨** (សាខាផ្សារព្រែកឯង) ដើម្បីពិនិត្យស្ថានភាពនៃដំណើរការបង្រៀន និងការរៀននាឱកាសបើកបវេសនកាលថ្មី ឆ្នាំសិក្សា២០២០-២០២១ ក្នុងបរិបទកូវីដ-១៩។

-ដឹកនាំក្រុមការងារជួបប្រជុំជាមួយ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបន្តពិភាក្សាលើការជំរុញអនុវត្តការអប់រំឌីជីថលឲ្យកាន់តែមានប្រសិទ្ធភាព និងស្តាប់នូវបទបង្ហាញការបង្កើត និងតម្លើង App E-Learning ដោយក្រុមការងារបច្ចេកទេស E-Learning។ ឈរលើមូលដ្ឋាននៃការគាំទ្រ និងការចូលរួមចំណែកផ្តល់ជាធាតុចូលជាបន្តបន្ទាប់ដល់ ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបង្កើតកម្មវិធីស្វ័យសិក្សា App E-Learning នេះ កាលពីថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២១ **ឯកឧត្តមប្រធានគណៈកម្មការ** និង **ឯកឧត្តមបណ្ឌិតសភាចារ្យ** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានចុះហត្ថលេខាលើ

សេចក្តីថ្លែងការណ៍រួមមួយ ប្រកាសដាក់ឲ្យប្រើប្រាស់នូវកម្មវិធីស្វ័យសិក្សានេះ ដែលមានឈ្មោះជាផ្លូវការថា "MoEYS\E-Learning" ។

-ចូលរួមជាគណៈអធិបតីក្នុងពិធីប្រកាសផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

-ជួបសំណេះសំណាល និងសម្តែងការគួរសមជាមួយ **ឯកឧត្តម ឈិត សុខុន** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា។

-ដឹកនាំប្រជុំគណៈកម្មាធិការធ្វើសេចក្តីព្រាងសេចក្តីប្រកាស ស្តីពីការធ្វើបច្ចុប្បន្នភាពការត្រៀមរៀបចំសេចក្តីព្រាងសេចក្តីប្រកាស នៃកិច្ចប្រជុំ អាសិប-១១ ASEP-11។

-អនុញ្ញាតឲ្យ **ឯកឧត្តម បាទ្រីក មើរហ្វី** (H.E Mr. W. Patrick Murphy) ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក **ឯកឧត្តម ប៉ាប្លូ កាង** (H.E Mr. Pablo Kang) ឯកអគ្គរដ្ឋទូតអូស្ត្រាលី **លោកជំទាវ ដេវ្យានី ខូប្រាហ្គាដ** (H.E. Dr. Devyani Khobragade) ឯកអគ្គរដ្ឋទូតឥណ្ឌា **លោកជំទាវ ទេវ ឡាយឆេង** (H.E. Ms. Teo Lay Cheng) ឯកអគ្គរដ្ឋទូតសិង្ហបុរី និង **ឯកឧត្តម មីកាមី ម៉ាហ្សាហ៊ីរ៉ូ** (MIKAMI Masahiro) ឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជា ជួបសម្តែងការគួរ និងពិភាក្សាការងារ។

-ចូលរួមកិច្ចប្រជុំជាមួយ គណៈកម្មការអប់រំ ទំនាក់ទំនង និងកិច្ចការវប្បធម៌ នៃក្រុមសភាជាតិកម្ពុជា **អាប៉េអេហ្វ** APF នៅវិមានព្រឹទ្ធសភា។

-បានជួបសំណេះសំណាល សួរសុខទុក្ខលោកគ្រូ អ្នកគ្រូ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សរុបប្រមាណ៣០នាក់ នៅមជ្ឈមណ្ឌលកីឡាព្រីមៀម (Premium Sport Club) ស្ថិតក្នុងខណ្ឌទួលគោក រាជធានីភ្នំពេញ ដោយមានវត្តមាន សិល្បករ សិល្បការិនីផ្សេងៗទៀតចូលរួម សរុប៣៦៨នាក់។

-បានដឹកនាំកិច្ចប្រជុំពីចម្ងាយជាមួយឯកឧត្តម លោកជំទាវ ជាសមាជិករដ្ឋសភាកម្ពុជា តាមរយៈប្រព័ន្ធវីដេអូ Zoom ដើម្បីធ្វើការពិភាក្សាលើការត្រៀមខ្លួនឈានឆ្ពោះទៅកាន់កិច្ចប្រជុំទ្វេភាគី រវាងសមាជិករដ្ឋសភាវ័យក្មេងកម្ពុជា និងសភាតំណាងប្រជាជនចិនទូទាំងប្រទេស ដោយបានផ្តោតជាពិសេសទៅលើសេចក្តីព្រាងប្រធានបទ របៀបវារៈនៃកិច្ចប្រជុំ និងការត្រៀមខ្លួនរបស់សមាជិកគណៈប្រតិភូលើទិដ្ឋភាព ខ្លឹមសារ និងបច្ចេកទេស។

-បានដឹកនាំគណៈប្រតិភូសភាវ័យក្មេងកម្ពុជា ប្រជុំតាមរយៈប្រព័ន្ធវីដេអូ ជាមួយគណៈប្រតិភូវ័យក្មេងសភាតំណាងប្រជាជនចិនទូទាំងប្រទេស និងបានពិភាក្សា និងចែករំលែកបទអន្តរាគមន៍ក្រោមប្រធានបទចំនួន៣ ដែលជាការឆ្លុះបញ្ចាំងនូវភាពរឹងមាំនៃចំណងមិត្តភាពកម្ពុជា-ចិន ក្នុងការកសាងសហគមន៍ជោគវាសនារួមដែលមានលក្ខណៈយុទ្ធសាស្ត្រ ជាពិសេសរវាងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងសភាតំណាងប្រជាជនចិនទូទាំងប្រទេស។

## ៨.គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

គណៈកម្មការទី៨នៃរដ្ឋសភា បាន៖

+ប្រជុំផ្ទៃក្នុងគណៈកម្មការ ចំនួន៣លើក ដើម្បីពិនិត្យពិភាក្សា៖ -លើការរៀបចំផែនការសកម្មភាព ក្នុងការចុះបំពេញបេសកកម្មទៅតាមបណ្តាខេត្ត -ខ្លឹមសារត្រៀមជួបជាមួយក្រសួងពាក់ព័ន្ធទាំង៤ និង -ពិនិត្យសេចក្តីព្រាងច្បាប់ស្តីពី វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

+ចូលរួមប្រជុំត្រៀមជាមួយសមភាគីសភាតំណាងប្រជាជនចិនទូទាំងប្រទេស ក្រោមអធិបតីភាព **លោកជំទាវកិត្តិសង្គហបណ្ឌិត** អនុប្រធានទី២នៃរដ្ឋសភា។

+រៀបចំ **"យុទ្ធនាការនារីវ័យក្មេងឆ្ពោះទៅភាពជាអ្នកដឹកនាំ ហ្គើលធូលីតឌ័រ #Girl2Leader"** ដែលប្រព្រឹត្តទៅនៅសាកលវិទ្យាល័យខេត្តក្រចេះ។

+ដឹកនាំកិច្ចប្រជុំនៃក្រុមពិភាក្សាទី៣ នៃកិច្ចប្រជុំអាសិប លើកទី១១ ចំនួន២លើក ដើម្បីរៀបចំខ្លឹមសារ តាមដានវឌ្ឍនភាពការងារ និងពិនិត្យសេចក្តីព្រាងបទអន្តរាគមន៍ ទៅក្នុងកិច្ចប្រជុំអាសិប លើកទី១១ ។

+ចូលរួមប្រជុំគណៈកម្មការជំនាញ នៃគណៈកម្មការអប់រំ ទំនាក់ទំនង និងកិច្ចការវប្បធម៌ នៃមហាសន្និបាតលើកទី៤៦ របស់សភានិយាយភាសាបារាំង អាប៉េអេហ្វ APF តាមរយៈប្រព័ន្ធវីដេអូ នៅវិមានព្រឹទ្ធសភា។

+ចូលរួមជាគណៈអធិបតីក្នុងពិធីប្រកាសផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ ។

+ចូលរួមថ្លែងលើប្រធានបទទី២ ក្នុងកិច្ចប្រជុំរវាងសភាកម្ពុជា ជាមួយសភាប្រជាជនចិនទូទាំងប្រទេស នៃសាធារណរដ្ឋប្រជាមានិតចិន តាមរយៈប្រព័ន្ធវីដេអូ នៅវិមានរដ្ឋសភា។

+អញ្ជើញ ឯកឧត្តម លោកជំទាវ ជារដ្ឋមន្ត្រី ព្រមទាំងសហការី ដែលជាតំណាងរាជរដ្ឋាភិបាល ចំនួន៤លើក រួមមាន៖ -ក្រសួងសុខាភិបាល -ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង -ក្រសួងកិច្ចការនារី ដើម្បីធ្វើសេចក្តីរាយការណ៍សង្ខេបអំពីវឌ្ឍនការងារ បញ្ហាប្រឈម ដែលក្រសួងបានជួបប្រទះក្នុងដំណាក់កូវីដ-១៩ និងទិសដៅការងារបន្តរបស់ក្រសួង ក្នុងឆ្នាំ ២០២១។

+ចុះបំពេញបេសកកម្ម ដើម្បីត្រួតពិនិត្យស្វែងយល់ប្រសិទ្ធភាព បញ្ហាប្រឈម និងទិសដៅបន្តរបស់វិស័យទាំង៤ ពិសេសស្វែងយល់អំពីប្រសិទ្ធភាពការងារក្រោយធ្វើប្រតិភូកម្មអំណាចនៃការគ្រប់គ្រងរដ្ឋបាលពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ នៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ និង ខេត្តកំពង់ធំ។

+ដឹកនាំគណៈប្រតិភូរដ្ឋសភាកម្ពុជា ចូលរួមសិក្ខាសាលាស្តីពី **"ធនធានៈនយោបាយទៅជាច្បាប់÷ ការលើកកម្ពស់ការគ្របដណ្តប់សុខភាពជាសកលនៅតំបន់អាហ្វ្រិក និងអាស៊ីប៉ាស៊ីហ្វិក"** តាមប្រព័ន្ធវីដេអូ ដែលតភ្ជាប់ពីវិមានរដ្ឋសភា ទៅកាន់ទីក្រុងហ្សឺណែវ ប្រទេសស្វីស។

+ដឹកនាំប្រជុំសហការជាមួយគណៈកម្មការទី៦នៃរដ្ឋសភា ជួបប្រជុំជាមួយ តំណាងរាជរដ្ឋាភិបាល រួមមាន ក្រសួងសុខាភិបាល និង ក្រសួងយុត្តិធម៌ ព្រមទាំងគណៈកម្មការជំនាញនានានៃរដ្ឋសភា ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី វិធានការទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

+ចូលរួមក្នុងកិច្ចប្រជុំតាមរយៈប្រព័ន្ធវីដេអូ ស្តីពី **"ស្ត្រី និងសេដ្ឋកិច្ចគ្រួសារជាស្នូល"** (គោលនយោបាយ កម្មវិធី និងបទពិសោធន៍ជោគជ័យ៖ ការត្រួតពិនិត្យច្បាប់ ការផ្តល់សិទ្ធិអំណាចដល់គ្រួសារ និងសក្តានុពលចលនាសេដ្ឋកិច្ច) ដែលភ្ជាប់ពីវិមានរដ្ឋសភា ទៅកាន់ទីក្រុងតេអ៊ីរ៉ង់ ប្រទេសអ៊ីរ៉ង់។

+ចូលរួមចុះបំពេញបេសកកម្មជាមួយគណៈកម្មការទី៣នៃរដ្ឋសភា នៅខេត្តកែប។

+ចូលរួមមហាសន្និបាតប្រចាំឆ្នាំនៃវេទិកាសភាអាស៊ី ដើម្បីប្រជារាស្ត្រ និងការអភិវឌ្ឍ តាមរយៈវីដេអូ ភ្ជាប់ពីវិមានរដ្ឋសភា ទៅកាន់ទីក្រុងតូក្យូ ប្រទេសជប៉ុន។

+ចូលរួម **ខ្ញុំប្រធានរដ្ឋសភា** ក្នុងកិច្ចប្រជុំទ្វេភាគីជាមួយ **ឯកឧត្តមប្រធានរដ្ឋសភាវៀតណាម**។

+ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ស្ត្រី និងសមភាពយេនឌ័រ អេអេហ្វភីភីឌី AFPPD តាមប្រព័ន្ធវីដេអូ ពីទីក្រុងតូក្យូ ប្រទេសជប៉ុន។

+ចូលរួមប្រជុំត្រៀមរៀបចំកិច្ចប្រជុំ អាយប៉ា AIPA លើកទី៤២។

+ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមអ្នកនយោបាយអាយប៉ា លើកទី១២ (12-AIPA Caucus) តាម ប្រព័ន្ធវីដេអូ ផ្សាយចេញពីប្រទេសសិង្ហបុរី។

+ចូលរួមសិក្ខាសាលាតាមប្រព័ន្ធវីដេអូ ស្តីពី "**ការស្តារឡើងវិញជីជំងឺរាតត្បាតកូវីដ-១៩ តាមរយៈចក្ខុវិស័យសិទ្ធិមនុស្ស៖ តើសភាមានការចូលរួមចំណែកអ្វីខ្លះ?**"។

## ៩.គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដីនគរូបនីយកម្ម និងសំណង់

គណៈកម្មការទី៩នៃរដ្ឋសភា បាន៖

+ប្រជុំផ្ទៃក្នុងគណៈកម្មការ ចំនួន៥លើក ដើម្បី៖ -ត្រួតពិនិត្យការងារអនុវត្តកន្លងមក ការកែសម្រួលសមាសភាព និងបែងចែងតួនាទីភារកិច្ចរបស់គណៈកម្មការ -រៀបចំផែនការសកម្មភាពបន្តរបស់គណៈកម្មការនាពេលវិស្សមកាលរបស់រដ្ឋសភា និង-ពិភាក្សាការងារចុះបំពេញបេសកកម្មរបស់គណៈកម្មការ នៅតាមបណ្តាខេត្តនានា។

+ដឹកនាំកិច្ចប្រជុំអនុគណៈកម្មការទី៣ (ឡូជីស្ទីក ពិធីការ និងបដិសណ្ឋារកិច្ច)នៃគណៈកម្មការរៀបចំកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប លើកទី១១ ASEP-11។

+គណៈកម្មការចុះបំពេញបេសកកម្ម នៅខេត្តសៀមរាប និងខេត្តបាត់ដំបង ដើម្បីស្វែងយល់ពីប្រសិទ្ធភាពនៃការប្រតិបត្តិច្បាប់នឹងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ របស់រដ្ឋបាលខេត្តដែលពាក់ព័ន្ធនឹងសមត្ថកិច្ចទទួលខុសត្រូវរបស់គណៈកម្មការ ពិនិត្យគម្រោងសាងសង់ផ្លូវ៣៨ខ្សែ និងស្ទឹងក្នុងខេត្តសៀមរាប និងពិនិត្យគម្រោងសាងសង់ព្រលានយន្តហោះថ្មី នៅខេត្តសៀមរាប។

+ដឹកនាំគណៈប្រតិភូចុះបំពេញបេសកកម្ម ចំនួន៥លើក ក្នុងនោះ៖

-បានចុះពិនិត្យមើលការផលិតអគ្គិសនី ប្រើដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៨០មេហ្គាវ៉ាត់ ស្ថិតនៅឃុំតំណាក់រាំង ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ដែលវិនិយោគដោយ ក្រុមហ៊ុន ស្នេរថេក ខូអិលធីឌី

-ចុះទស្សនកិច្ចសិក្សាស្វែងយល់ពីការផលិតអគ្គិសនីដើរដោយប្រេងខ្មៅ និងឧស្ម័ន ស្ថិតនៅក្នុងស្រុកល្វាឯម ខេត្តកណ្តាល

-បានចុះសិក្សាស្វែងយល់ពីវឌ្ឍនភាពនៃការបូមប្រេងរបស់ ក្រុមហ៊ុន គ្រីស អ៊ីនើជី Kris Energy រួមជាមួយតំណាងក្រសួងរ៉ែ និងថាមពល និងតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅតំបន់ប្លុកA ក្នុងឈូងសមុទ្រកម្ពុជា នាខេត្តព្រះសីហនុ និង

-បានចុះពិនិត្យគម្រោងសាងសង់ព្រលានយន្តហោះអន្តរជាតិថ្មី នៅខេត្តសៀមរាប

-បានចុះពិនិត្យវឌ្ឍនភាពការងារសាងសង់ផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ-កំពង់ផែស្វយ័តក្រុងព្រះសីហនុ ផ្លូវលេខ១៤៦B និងផ្លូវជាតិលេខ៣ នៅខេត្តព្រះសីហនុ ដែលជាភារកិច្ចទទួលខុសត្រូវរបស់គណៈកម្មការទី៩នៃរដ្ឋសភា។

+ចូលរួមពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១ នៅក្រសួងសាធារណការ និងដឹកជញ្ជូន។

+ប្រជុំផ្ទៃក្នុងគណៈកម្មការ ប្រជុំជាមួយបណ្ដាគណៈកម្មការនានានៃរដ្ឋសភា និងប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសេចក្ដីព្រាងច្បាប់ចំនួន៤ ដែលគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាប្រគល់ជូនគណៈកម្មការពិនិត្យសិក្សា។

+ដឹកនាំប្រជុំផ្ទៃក្នុងគណៈកម្មការ តាមរយៈប្រព័ន្ធវីដេអូ ដើម្បីពិនិត្យពិភាក្សាសេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រម លើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់។

+ចូលរួមប្រជុំត្រៀមការចូលរួមមហាសន្និបាតអាយប៉ាលើកទី៤២ និងត្រៀមរៀបចំមហាសន្និបាតលើកទី៤៣។

+ចូលរួមប្រជុំជាមួយគណៈកម្មការទី២ និងតំណាងរាជរដ្ឋាភិបាល តាមប្រព័ន្ធវីដេអូ ដើម្បីពិនិត្យសិក្សាសេចក្ដីព្រាងច្បាប់ ចំនួន២។

## ១០.គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ

គណៈកម្មការទី១០នៃរដ្ឋសភា បាន៖

+ចូលរួមជាមួយគណៈប្រតិភូក្រុមសភាជាតិកម្ពុជា ចូលរួមមហាសន្និបាតលើកទី៤៦ នៃសភានិយាយភាសាបារាំង អាប៉េអេហ្វ APF តាមប្រព័ន្ធវីដេអូ ដែលផ្សាយចេញពីទីក្រុងប៉ារីស ប្រទេសបារាំង។

+ចូលរួមប្រជុំគណៈកម្មាធិការ ធ្វើសេចក្ដីព្រាងច្បាប់សេចក្ដីប្រកាស ស្ដីពីការធ្វើបច្ចុប្បន្នភាពការត្រៀមកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប លើកទី១១ ចំនួន២លើក។

+បានដឹកនាំកិច្ចប្រជុំដើម្បីពិនិត្យ និងពិភាក្សាទៅលើខ្លឹមសារមួយចំនួន សម្រាប់ក្រុមពិភាក្សាទី១នៃកិច្ចប្រជុំអាសិប លើកទី១១ ASEP-11 ដោយមានសមាជិកមកពីតំណាងគណៈកម្មការនានាចូលរួម។

+ចូលរួមជាវាគ្មិនក្នុងវេទិកា ស្ដីពីយុទ្ធនាការនារីវ័យក្មេងឆ្ពោះទៅភាពជាអ្នកដឹកនាំ នៅខេត្តក្រចេះ។

+ចូលរួមសវនាការសភា នៅអង្គការសហប្រជាជាតិសម្រាប់ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ ស្ដីពីការប្រយុទ្ធប្រឆាំងអំពើពុករលួយ ដើម្បីស្តារឡើងវិញនូវទំនុកចិត្តលើរដ្ឋាភិបាល និងធ្វើឲ្យប្រសើរឡើងនូវទស្សនវិស័យនៃការអភិវឌ្ឍ។

+ចូលរួមកិច្ចប្រជុំរវាងសភាសភាជិកអាយប៉ា និងសភានៃព្រះរាជាណាចក្រណ័រវេ តាមប្រព័ន្ធវីដេអូ។

+ចូលរួម **"កិច្ចប្រជុំអន្តរតំបន់រវាងសភាអារ៉ាប់ និងសភាអាស៊ី ដើម្បីតាមដានការប្ដេជ្ញាចិត្តក្នុងការអនុវត្ត អាយស៊ីភីឌី២៥ ICPD25"** តាមប្រព័ន្ធវីដេអូ ផ្សាយចេញពីទីក្រុងបេរូត ប្រទេសលីបង់ ដែលរៀបចំដោយសមាគមអាស៊ីដើម្បីប្រជាជន និងការអភិវឌ្ឍ APDA, JPFP, UNFPA និង JTF។

+ដឹកនាំប្រជុំក្រុមការងារ ដើម្បីពិនិត្យខ្លឹមសារឯកសារសម្រាប់ចូលរួមកិច្ចប្រជុំក្រុមការងារ **អាយប៉ា អាដហុក** (AIPA Ad-Hoc Working Group Meeting) ទៅលើសេចក្តីព្រាងសេចក្តីសម្រេច ស្តីពីការផ្លាស់ប្តូរលេខាធិការដ្ឋានអាយប៉ា AIPA។

+បានដឹកនាំគណៈប្រតិភូសភាកម្ពុជា ចូលរួមកិច្ចប្រជុំជាមួយក្រុមការងារជំនាញ **អាយប៉ា** (Ad-Hoc Working Group) លើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី **"ការផ្លាស់ប្តូរលេខាធិការដ្ឋានអាយប៉ា"** តាមប្រព័ន្ធវីដេអូដែលផ្សាយចេញពីទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី មកកាន់រដ្ឋសភាកម្ពុជា។

+ចូលរួមកិច្ចប្រជុំគណៈកម្មាធិការកិច្ចការអចិន្ត្រៃយ៍ស្ត្រី និងសមភាពយេនឌ័រ នៃវេទិកាសមាជិកសភាអាស៊ី ដើម្បីប្រជារាស្ត្រ និងការអភិវឌ្ឍ ក្រោមប្រធានបទ **"គម្រោយផ្លូវដើម្បីបញ្ចប់អាពាហ៍ពិពាហ៍កុមារ"** តាមប្រព័ន្ធវីដេអូ ដែលផ្សាយចេញពីទីក្រុងតូក្យូ ប្រទេសជប៉ុន។

+ចូលរួមប្រជុំត្រៀមរៀបចំកិច្ចប្រជុំ អាយប៉ា AIPA លើកទី៤២។

+ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមអ្នកនយោបាយអាយប៉ា លើកទី១២ (12-AIPA Caucus) តាម ប្រព័ន្ធវីដេអូ ផ្សាយចេញពីប្រទេសសិង្ហបុរី។

## VI.សកម្មភាពរបស់សមាជិក សមាជិការដ្ឋសភា

នៅក្នុងឱកាសវិសមកាលនៃរដ្ឋសភាទើបកន្លងទៅនេះ សមាជិករដ្ឋសភាគ្រប់រូប បានប្រឹងប្រែងយ៉ាងសកម្មខ្លាំងក្លាចុះមូលដ្ឋាន សួរសុខទុក្ខ ទទួលសំណូមពរ និងខិតខំដោះស្រាយរាល់បញ្ហារបស់ពលរដ្ឋជាម្ចាស់ឆ្នោត។ សកម្មភាពលេចធ្លោ ក្នុងការងារចុះមូលដ្ឋាន ខាងលើនេះ មានជាអាទិ៍៖

ចូលរួមធ្វើការងារផ្សព្វផ្សាយដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ស្របតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលមានក្រសួងសុខាភិបាល ជាសេនាធិការ ។ ដោយឡែក សមាជិករដ្ឋសភាយើងក៏បានចុះសួរសុខទុក្ខផ្ទាល់ ហើយបានចូលរួមជាមួយរាជរដ្ឋាភិបាល រួមមានទាំងថ្នាក់ជាតិ និងក្រោមជាតិដោយបានដោះស្រាយជាសម្ភារៈផ្សេងៗ ដល់អ្នកខ្វះខាតក្នុងអំឡុងកូវីដ-១៩ រាតត្បាតនេះ។ ជាមួយនោះ តំណាងរាស្ត្រយើង ក៏បានចូលរួមបំផុសឲ្យប្រជាពលរដ្ឋឲ្យរៀបចំការរស់នៅតាមរបៀបថ្មី ក្នុងសភាពដែលកូវីដ-១៩ កំពុងរាតត្បាត តាមរយៈវិធានការរដ្ឋាភិបាល **៣ការពារ ៣កុំ** រួមជាមួយនឹង **ការចាក់វ៉ាក់សាំង** ទៅតាមផែនការដែលចាត់ចែងដោយរាជរដ្ឋាភិបាល។ ក្នុងនោះដែរ ការចូលរួមក្នុងវេទិកាអន្តរជាតិជាច្រើន តាមរយៈប្រព័ន្ធវីដេអូ ដែលភ្ជាប់ពីវិមានរដ្ឋសភា ទៅកាន់បណ្តាប្រទេសនានាលើពិភពលោក សមាជិករដ្ឋសភាយើងក៏បានលើកពីកិច្ចសហប្រតិបត្តិការគ្នាក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ដែលបានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះសង្គម និងសេដ្ឋកិច្ចសកលលោក។

ចំពោះការចុះសួរសុខទុក្ខប្រជាពលរដ្ឋនៅតាមមូលដ្ឋាន និងសកម្មភាពផ្សេងៗរបស់សមាជិក សមាជិការដ្ឋសភា គឺមានសកម្មភាពច្រើនណាស់។ ខ្ញុំសូមអភ័យទោសដោយពុំអាចរៀបរាប់ក្នុងរបាយការណ៍សង្ខេបនេះ ប៉ុន្តែមាននៅក្នុងរបាយការណ៍លម្អិត ដូចបានចែកជូនរួចហើយ។

**អង្គសភាជាទីគោរព !**

រដ្ឋសភាយើងបានឈរលើជំហរទទួលខុសត្រូវខ្ពស់ និងតម្កល់ផលប្រយោជន៍ប្រជាពលរដ្ឋជាធំ ក្នុងការកសាងច្បាប់ដោយផ្អែកលើស្មារតីផ្សះផ្សា បង្រួបបង្រួមជាតិ ក្នុងគោលដៅចម្បងបំផុត គឺស្វែងរកសេចក្តីសុខ សន្តិភាព យុត្តិធម៌សង្គម ឯករាជ្យ អព្យាក្រឹត្យ ការពារបូរណភាពទឹកដី និងភាពសម្បូរណ៍រុងរឿង ជូនមាតុភូមិជាទីស្រឡាញ់របស់យើងទាំងអស់គ្នា។

ក្នុងឱកាសនេះ ក្នុងនាម **ខ្ញុំប្រធានរដ្ឋសភា** ខ្ញុំសូមកោតសរសើរយ៉ាងស្មោះស្ម័គ្រ ចំពោះតំណាងរាស្ត្រទាំងអស់ដែលបានយកចិត្តទុកដាក់បំពេញភារកិច្ច និងតួនាទីរបស់ខ្លួនដោយពុំខ្លាចនឿយហត់ ឬគិតពីនិន្នាការនយោបាយអ្វីឡើយ ដើម្បីផលប្រយោជន៍ប្រជាពលរដ្ឋ និងផលប្រយោជន៍ប្រទេសជាតិ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះស្ថាប័នរដ្ឋទាំងអស់ ជាអាទិ៍ រាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ព្រមទាំងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ដែលបានសហការល្អ បង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងឲ្យគណៈកម្មការនានារបស់រដ្ឋសភា គណៈប្រតិភូរដ្ឋសភា ក៏ដូចជាតំណាងរាស្ត្របានជួបសំណេះសំណាល ប្រាស្រ័យការងារ និងសួរសុខទុក្ខប្រជារាស្ត្រនៅតាមមូលដ្ឋាន។

នៅទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសូមជូនពរ សមាជិក សមាជិការដ្ឋសភាយើងទាំងអស់ បានប្រកបតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**